ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# បទដ្ឋានអនុវត្តបច្ចេកវិទ្យា

# ការជ្រើសរើសពូជស្រូវសំរាប់ការដាំដុះតំបន់ទំនាបរំពឹងទឹកភ្លៀង




រៀបចំដោយ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

សហការជាមួយ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

ឧបត្ថម្ភដោយ គំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី

រៀបរៀងដោយៈ លោក ពិត ខុនហែល
វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
ទូរស័ព្ទៈ ០១២ ៥៨៥៨៩២
អ៊ីម៉ែលៈ PBREED@cardi.org.kh

កាលបរិច្ឆេទ ខែ កុម្ភៈ ឆ្នាំ ២០០៦

© រក្សាសិទ្ធិគ្រប់យ៉ាង គ្រប់បទដ្ឋានអនុវត្តបច្ចេកវិទ្យា (បអប) ទាំងអស់រួមទាំងឯកសារនេះ ជាកម្មសិទ្ធិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយសំរេចផ្តល់អោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ធ្វើជាម្ចាស់កម្មសិទ្ធិ។ រាល់សំណើសុំផលិតបន្ថែមត្រូវសុំការអនុញ្ញាតសិទ្ធិជាមុន ពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

## អារម្ភកថា

ពាក្យពេញនៃ **បអប** គឺ “បទដ្ឋានអនុវត្តបច្ចេកវិទ្យា”។ បអប ពន្យល់ពីរបៀបអនុវត្តបច្ចេកវិទ្យា ដើម្បីជួយដោះស្រាយបញ្ហាផ្នែកកសិកម្មរបស់កសិករ។ បអប ផ្ទុកនូវព័ត៌មានបទដ្ឋាន និងសំភារៈសម្រាប់ឱ្យមន្ត្រីផ្សព្វផ្សាយផ្ទេរបច្ចេកវិទ្យានេះទៅកសិករ។ គោលគំនិតនៃបអប គឺដើម្បីផ្សព្វផ្សាយដល់ឃុំ ស្រុក និងខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ បអប ត្រូវបានគេសរសេរសម្រាប់អោយមន្ត្រីផ្សព្វផ្សាយ អង្គការក្រៅរដ្ឋាភិបាល និងផ្នែកផ្សេងៗ ទៀតដែលបំរើការនៅក្នុងវិស័យអភិវឌ្ឍន៍កសិកម្ម នៅតាមមូលដ្ឋានប្រើប្រាស់។ បអប មានលក្ខណៈដូចខាងក្រោមនេះ៖

- អាចបត់បែនបាន-បអប អាចយកទៅអនុវត្តបាននៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា
- សាមញ្ញ-បអប អាចប្រើប្រាស់បានដោយគ្រប់ផ្នែកដែលបំរើការនៅតាមមូលដ្ឋាន
- ងាយយល់-ងាយស្រួលក្នុងការផ្តល់នូវព័ត៌មានសំខាន់ៗ

បអប ត្រូវបានកំណត់អាទិភាពដោយផ្អែកទៅតាមបញ្ហាផ្នែកកសិកម្មសំខាន់ៗរបស់កសិករតាមរយៈប្រភពជាច្រើនដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (FSMIS) ដែលផ្ទុកនូវព័ត៌មានសំខាន់ៗរបស់កសិករ។ បញ្ហាផ្នែកកសិកម្មរបស់កសិករត្រូវបានគេវិភាគតាមរយៈការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថាន ថ្នាក់ឃុំ (AEA) នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ បអប មាននៅតាមស្ថាប័ននានា ដូចខាងក្រោមៈ

- វិទ្យាស្ថានស្រាវជ្រាវជាតិ
- ក្រុមកសិករ
- អង្គការក្រៅរដ្ឋាភិបាល
- ទីភ្នាក់ងារស្រាវជ្រាវអន្តរជាតិ
- កម្មវិធីផ្សព្វផ្សាយ
- ម្ចាស់ជំនួយ
- ផ្នែកឯកជន

បអប ត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បអប ត្រូវបានសរសេរដោយអ្នកឯកទេសដែលមានបទពិសោធន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដូច្នេះ បអប ផ្ទុកនូវបទពិសោធន៍ល្អៗសម្រាប់អនុវត្តបច្ចេកវិទ្យា។ បអប ត្រូវបានឆ្លងកាត់ការត្រួតពិនិត្យរបស់ក្រុមការងារ បអប បន្ទាប់មកអនុម័ត និងអនុញ្ញាតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ប្រើប្រាស់នៅតាមមូលដ្ឋាន។

## បុព្វកថា

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រោមកិច្ចសហការគាំទ្រពីទីភ្នាក់ងារអូស្ត្រាលីសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (AusAID)តាមរយៈគំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី ជំហានទី២ (២០០១-២០០៦) ដែលមានគោលដៅពង្រឹងស្ថាប័ន និងប្រព័ន្ធផ្សព្វផ្សាយកសិកម្មនៅកម្ពុជា បានខិតខំយ៉ាងពេញទំហឹងដើម្បីធ្វើការពង្រឹងសមត្ថភាពមន្ត្រីផ្សព្វផ្សាយកសិកម្ម ការរៀបចំកសាងផែនការផ្សព្វផ្សាយកសិកម្មស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល តាមរយៈការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានថ្នាក់ឃុំ សង្កាត់ និងបានចងក្រងជាបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះឡើង។

បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ បានចងក្រងដោយអ្នកជំនាញឯកទេស (Subject Matter Specialist) នឹងត្រូវបានឆ្លងការពិនិត្យ ពិគ្រោះយោបល់ និងឯកភាពយល់ព្រមពីគណៈកម្មការបច្ចេកទេសដែលមានសមាសភាពមកពីនាយកដ្ឋានជំនាញនានា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងអ្នកពាក់ពន្ធ័ផ្សេងៗទៀត។ ឯកសារដ៏មានសារៈសំខាន់នេះ គឺជាឯកសារគោលដែលពិពណ៌នាអំពី ព័ត៌មាន បច្ចេកទេស វិធីសាស្ត្រ នីតិវិធី និងផែនការថវិកាចំណាយសម្រាប់ជួយដល់មន្ត្រីកសិកម្មស្រុក និងភ្នាក់ងារប្រតិបត្តិនៅមូលដ្ឋាននានាយកទៅប្រើប្រាស់ក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ក្នុងបំណងផ្ទេរចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មតាមគ្រប់រូបភាពឱ្យបានជ្រួតជ្រាបដល់ប្រជាកសិករ និងផលិតករ ដែលរស់នៅក្នុងតំបន់មានសក្តានុពលភាពស្របតាមលក្ខខ័ណ្ឌភូមិសាស្ត្រ សេដ្ឋកិច្ចសង្គម និង តម្រូវការចាំបាច់ជាក់ លាក់នៅមូលដ្ឋាន ។

ដូច្នេះបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ មានសារៈប្រយោជន៍ជារួមសម្រាប់មន្ត្រីកសិកម្មខេត្ត-ក្រុង យកទៅប្រើប្រាស់ក្នុងការចូលរួមដោះស្រាយបញ្ហាចំពោះមុខ ដែលប្រជាកសិករយើងកំពុងប្រឈមមុខនៅក្នុងការធ្វើផលិតកម្មកសិកម្ម ពិពិធកម្មកសិកម្ម ដើម្បីធានាសន្តិសុខស្បៀង និងបង្កើនប្រាក់ចំណូលគ្រួសារ ជាពិសេសរួមចំណែកកាត់បន្ថយភាពក្រីក្រស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គាំទ្រនូវឯកសារបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះដែលជាឯកសារគោលសម្រាប់មន្ត្រីកសិកម្មស្រុក ខេត្ត-ក្រុង អង្គការក្រៅរដ្ឋាភិបាល ភ្នាក់ងារប្រតិបត្តិនានានៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់យកទៅអនុវត្តក្នុងការផ្ទេរបច្ចេកវិទ្យាដល់ប្រជាកសិករនៅជនបទឱ្យទូលំទូលាយ និង ទទួលបានផ្លែផ្កាល្អប្រសើរប្រកបដោយក្តីសង្ឃឹម។

**រដ្ឋមន្ត្រី**

# មាតិការអត្ថបទ


**១. អធិប្បាយទូទៅ** ........ ១

**២. គោលការណ៍បច្ចេកទេស** ........ ១

**២.១ សេចក្តីផ្តើម** ........ ១

**២.២. ប្រព័ន្ធអេក្វូត្របរិស្ថានដំណាំស្រូវនៅក្នុងប្រទេសកម្ពុជា** ........ ***វីរ្យុវា ញ្ញុំកមារក ឡុត ដាចិនដេ ។***

*២.២.១ ដំណាំស្រូវចំការ :* ........ ៣

*២.២.២ ដំណាំស្រូវទំនាបអាស្រ័យទឹកភ្លៀង :* ........ ៣

*២.២.៣ ដំណាំស្រូវឡើងទឹក :* ........ ៤

*២.២.៤. ដំណាំស្រូវប្រាំង ស្រូវប្រដេញទឹក:* ........ ៥

**២.៣ ការពិពណ៌នាអំពីលក្ខណៈរបស់ពូជស្រូវដែលត្រូវជ្រើសរើសដើម្បីដាំដុះ** ........ ៥

**៣. ជំហ៊ាននៃការជ្រើសរើសពូជស្រូវនៅតំបន់ទំនាបនិងសំនួរគន្លឹះដែលទាក់ទងនឹងប្រព័ន្ធអេក្វូត្របរិស្ថានដំណាំស្រូវ** ........ ១០

**៣.១. សំនួរគន្លឹះសំរាប់ការជ្រើសរើសប្រភេទពូជស្រូវនៅតំបន់ទំនាបពឹងទឹកភ្លៀង** ........ ***វីរ្យុវា ញ្ញុំកមារក ឡុត ដាចិនដេ ។***

*៣.១.១ គន្លឹះទី១: ការជ្រើសរើសប្រភេទពូជស្រូវនៅតំបន់ទំនាបខ្ពស់ពឹងទឹកភ្លៀង* ........ ១០

*៣.១.២ គន្លឹះទី២: ជ្រើសរើសប្រភេទពូជស្រូវនៅតំបន់ទំនាបកណ្តាលពឹងទឹកភ្លៀង* ........ ១២

*៣.១.៣ គន្លឹះទី៣: ការជ្រើសរើសប្រភេទពូជស្រូវនៅតំបន់ទំនាបទាប(ស្រែជម្រៅ) ពឹងទឹកភ្លៀង* ........ ១៣

**៣.២ ការផ្សព្វផ្សាយពូជក្នុងសហគមន៍កសិករ** ........ ១៥

**៣.៣. ការចំណាយលើការងារផ្សព្វផ្សាយ** ........ ១៨

**៣.៤. តម្រូវការធនធាននៅក្នុងការងារផ្សព្វផ្សាយ** ........ ២០

**៣.៥ ឱកាសសម្រាប់ការធ្វើបន្ទាញ** ........ ២១

**៤. លក្ខណៈសំខាន់ៗរបស់ពូជស្រូវដែលរំដោះវិទ្យាស្ថាន** ........ ២៥

**៤.១. ពូជស្រូវសំរាប់តំបន់ទំនាបខ្ពស់ (ស្រែលើ)** ........ ២៥

**៤.២. ពូជស្រូវសំរាប់តំបន់ទំនាបកណ្តាល (ស្រែកណ្តាល)** ........ ២៦

**៤.៣. ពូជស្រូវសំរាប់តំបន់ទំនាបទាប (ស្រែជំរៅ)** ........ ២៧

## ១. ការអធិប្បាយទូទៅ

ការយល់ដឹងអំពីការជ្រើសរើសពូជស្រូវរំដោះសំរាប់ការដាំដុះសមស្របទៅតាមកេ្សត្របរិស្ថាន គឺជាការងារមួយសំខាន់សម្រាប់កសិករភាគច្រើនទោះបីស្ថិតក្នុងកាលៈទេសៈសមស្របយ៉ាងណាក៏ដោយ ។ នៅប្រទេសកម្ពុជាកិច្ចការនេះវានឹងរឹតតែលំបាកទៅទៀត ដោយសារយើងខ្វះខាតនូវព័តិមាននានាសម្រាប់ការងារនេះ ។ ការយល់ដឹងអំពីការជ្រើសរើសពូជស្រូវរំដោះ និងការប្រើប្រាស់ពូជសម្រាប់ផលិតកម្មស្រូវនៅកម្ពុជា ជាបញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើន។

ឯកសារចងក្រងនេះផ្តល់នូវវិធីសាស្ត្រដ៏ងាយស្រួលមួយ ដើម្បីធ្វើការជ្រើសរើសពូជស្រូវសម្រាប់ការដាំដុះ។ គន្លឹះនៃការជ្រើសរើសពូជមានភាពសាមញ្ញក្នុងការប្រើប្រាស់លើកេ្សត្របរិស្ថានស្រែទំនាបរំពឹងទឹកភ្លៀង។

បន្ថែមពីលើនេះទៀត មន្ត្រីកេ្សត្រសាស្ត្រ និងផ្សព្វផ្សាយកសិកម្មថ្នាក់ខេត្ត/ក្រុង និងថ្នាក់ស្រុក នឹងប្រើប្រាស់ឯកសារនេះ ជាជំនួយធ្វើឱ្យមានការរីកចំរើនដល់កសិករក្នុងការអនុវត្តន៍ទៅលើការប្រើប្រាស់ពូជ ។ ឯកសារចងក្រងនេះនឹងមានសារៈប្រយោជន៍ផងដែរ នៅតាមបណ្តាខេត្ត សាកលវិទ្យាល័យ មហាវិទ្យាល័យ និងសាលាកសិកម្មនានាដើម្បីជាទុនសម្រាប់ការស្រាវជ្រាវ ។ ជាទូទៅ គឺអាចធ្វើនៅគ្រប់ទីកន្លែងដាំដុះស្រូវក្នុងប្រទេសកម្ពុជា ។

### គោលបំណង និងសារៈប្រយោជន៍

-ផ្តល់នូវគោលការណ៍បច្ចេកទេស និងផ្សព្វផ្សាយនូវការជ្រើសរើសពូជស្រូវដែលរំដោះដើម្បីដាំដុះអោយបានត្រឹមត្រូវទៅតាមប្រព័ន្ធកេ្សត្រ-បរិស្ថាន ។

-ជ្រើសរើសពូជស្រូវរំដោះអោយបានសមស្របទៅតាមតម្រូវការ និងការនិយមចូលចិត្តរបស់កសិករ ។

-ពិពណ៌នាអំពីលក្ខណៈពិសេសសំខាន់ៗរបស់ពូជស្រូវរំដោះ ។

## ២. គោលការណ៍បច្ចេកទេស

### ២.១ សេចក្តីផ្តើម

ស្រូវជាដំណាំស្បៀងយ៉ាងសំខាន់បំផុតរបស់ប្រជាជនកម្ពុជា ។ មានពូជស្រូវរាប់ពាន់ពូជដែលបានធ្វើការដាំដុះដោយប្រជាកសិករកម្ពុជាក្នុងបរិស្ថានដាំដុះខុសៗពីគ្នា ចាប់តាំងពីស្រូវចំការ ស្រូវតំបន់ទំនាបទីពឹងទឹកភ្លៀង ស្រូវតំបន់ស្រោចស្រព និងស្រូវឡើងទឹក។ ពូជស្រូវប្រពៃណីទាំងនោះកសិករនិយមចូលចិត្តដាំដុះទៅតាមតំបន់ តាមទំលាប់តៗគ្នាពីដូនតា តាមលក្ខណៈនិងគុណភាពរបស់ពូជ និងភាពបន្សាំរបស់ពូជទៅតាមប្រភេទដី។ ដើម្បីបំពេញតំរូវការស្បៀងអាហារ និងបង្កើនប្រាក់ចំណូលក្នុងគ្រួសារតាមរយៈតំរូវការទីផ្សារ ការជ្រើសរើសយកពូជស្រូវដែលសមស្របទៅនឹងលក្ខខ័ណ្ឌរបស់កសិករនៅតាមតំបន់ផ្សេងៗ គឺជាបញ្ហាចំបង។

ចាប់តាំងពីឆ្នាំ ១៩៨៩ កម្មវិធីកម្ពុជា-អ៊ីរី-អូស្ត្រាលី បានបង្កើតកម្មវិធីរុក្ខជំរើសវិទ្យារបស់គំរោងដោយប្រើប្រាស់ធនធានមនុស្សក្នុងស្រុក និងសហការជាមួយកម្មវិធីស្រាវជ្រាវអន្តរជាតិមួយចំនួនដូចជា វិទ្យាស្ថានអន្តរជាតិផ្នែកស្រាវជ្រាវអំពីដំណាំស្រូវ (IRRI) កម្មវិធីផ្ទាលអន្តរជាតិ (INGER) សមូហកម្មជីវករ និងកម្មវិធីស្រាវជ្រាវអំពីដំណាំស្រូវនៃប្រទេសផ្សេងៗទៀត ដើម្បីធ្វើការស្រាវជ្រាវជ្រើសរើសពូជស្រូវដែលផ្តល់នូវទិន្នផលខ្ពស់ និងសមស្របទៅនឹងលក្ខខ័ណ្ឌក្នុងប្រទេសកម្ពុជា ។ ការពិសោធន៍ពូជស្រូវជាច្រើនជំហានដែលត្រូវបានធ្វើឡើងមានការពិសោធន៍

តាមដានទិន្នផល ពិសោធន៍ប្រៀបធៀបទិន្នផលបឋម ពិសោធន៍ជំរើសទិន្នផល និងពិសោធន៍បន្សាំលើស្រែកសិករ ។ មុននឹងឈានដល់ជំហានទីបួន(ពិសោធន៍បន្សាំលើស្រែកសិករ)ពូជដែលរំពឹងថាល្អដែលជ្រើសរើសបានពីជំហានទីបីត្រូវបានគេ លើកជាសំណូមពរទៅកាន់គណៈកម្មាធិការជាតិអនុសាសន៍ពូជ ដើម្បីធ្វើការរំដោះ ។

គណៈកម្មាធិការជាតិអនុសាសន៍ពូជត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩០ ។ គណៈកម្មាធិការនេះដំបូងស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានក្សេត្រសាស្ត្រ ដែលមានសមាសភាពជាប្រធាន១នាក់ លេខាធិការ១នាក់ និងសមាជិកជាច្រើនរូប ដែលជាអ្នកបច្ចេកទេសកសិកម្មមកពីនាយកដ្ឋានក្សេត្រសាស្ត្រ មន្ទីរកសិកម្មខេត្តនានា អ្នកបច្ចេកទេសកសិកម្មមកពីអង្គការនានាដែលធ្វើការជាមួយដំណាំស្រូវ ។ គណៈកម្មាធិការនេះមានតួនាទីក្នុងការពិនិត្យ វិភាគ និងសំរេចទៅ លើសក្តានុពល ទិន្នផល និងគុណភាពរបស់ពូជដំណាំ ដោយយោងទៅលើទិន្នន័យប្រវត្តិនៃការពិសោធន៍របស់ពូជ នីមួយៗ និងធ្វើការដាក់ឈ្មោះថ្មី ហើយសំរេចធ្វើការរំដោះជាផ្លូវការអោយកសិករប្រើប្រាស់ ។

ចាប់តាំងពីឆ្នាំ ១៩៨៩មកពូជស្រូវចំនួន៣៥ពូជត្រូវបានរំដោះជាបន្តបន្ទាប់ ផ្អែកទៅលើលក្ខណៈវិនិច្ឆ័យនៃទិន្នផលខ្ពស់ គុណភាពអង្ករល្អ បាយឆ្ងាញ់ បាយឡើង ប្រភេទក្តួរស្រូវល្អ គ្រាប់អង្ករល្អ គ្រាប់ថ្លារលូន ភាពសពោះភាគរយអង្ករកិន ភាពធន់ទ្រាំនឹងជំងឺ និងសត្វល្អិត និងជូនដល់កសិករធ្វើការដាំដុះ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ពូជស្រូវទាំង៣៥ពូជនេះមាន ២៥ពូជ មានលក្ខណៈសម្បត្តិសមស្របទៅនឹងបរិស្ថានស្រែទំនាបទីពឹងទឹកភ្លៀង ២ពូជមានលក្ខណៈសម្បត្តិសមស្របទៅនឹងបរិស្ថានស្រូវចំការ ៣ពូជសមស្របទៅនឹងបរិស្ថានស្រូវឡើងទឹក និង៩ពូជសមស្របទៅនឹងស្រូវប្រាំង និង ស្រូវប្រដេញទឹក ។

**ការកំណត់លក្ខណៈសំខាន់របស់ដំណាំស្រូវដើម្បីធ្វើការជ្រើសរើសពូជសំរាប់ការដាំដុះ** បន្ទាប់ពីចង់បានទិន្នផលខ្ពស់មានលក្ខណៈសំខាន់ជាច្រើនទៀតដែលប្រជាកសិករត្រូវធ្វើការជ្រើសយកជាអាទិភាពចំបងក្នុងការងារផលិតកម្មរបស់គាត់ ដូចជា គុណភាពអង្ករល្អ រសជាតិ អង្ករឡើងបាយ គ្រាប់អង្ករល្អ គ្រាប់ថ្លា រលូន អត្រាកិនជាអង្ករខ្ពស់ ភាពដួលដើម ភាពងាយបោកបែន ។

១-ប្រជាកសិករ គប្បីជ្រើសរើសពូជស្រូវណាដែលល្អសមស្រប និងឆ្លើយតបទៅនឹងក្សេត្របរិស្ថានដាំដុះរបស់ខ្លួន ។

២-ត្រូវធ្វើការសំរេចចិត្ត និងជ្រើសរើសពូជដែលមានគុណភាពឆ្លើយតបទៅនឹងតំរូវការនៃទីផ្សារ ទាំងទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ ។

៣-ជ្រើសរើសពូជដែលធន់ទ្រាំទៅនឹងជម្ងឺ និងសត្វល្អិត ។

## ២.២. ប្រព័ន្ធអេកូឡូស៊ីស្រែក្នុងប្រទេសកម្ពុជា




ពូជស្រូវទាំងអស់ដែលដាំដុះនៅព្រះរាជាណាចក្រកម្ពុជាបានធ្វើការបែងចែកទៅតាមប្រភេទនៃវេទរសភាព នឹងរយៈពន្លឺ (ភាពប្រកាន់រដូវ) អាយុកាល ពេលវេលាចេញផ្កា និងក្លិនក្រអូបរបស់ពូជ ។

អេកូឡូស៊ីដាំដុះស្រូវនៃរាជាណាចក្រកម្ពុជាបានបែងចែកទៅតាមសណ្ឋានដីដោយមានការប្រែប្រួលយ៉ាងខ្លាំងពីតំបន់ភ្នំទៅទំនាបលិចទឹកជ្រៅ គឺមាន ស្រូវចំការ ស្រូវទំនាបទីពឹងទឹកភ្លៀង និង ស្រូវឡើងទឹក ។

### ២.២.១ ដំណាំស្រូវចំការ

ស្រូវប្រភេទនេះត្រូវបានដាំដុះនៅក្នុងស្រែដែលគ្មានភ្លឺ ហើយទីពឹងរបបទឹកភ្លៀងទាំងស្រុង ដែលមានផ្ទៃដីប្រមាណ២% នៃផ្ទៃដីដាំដុះសរុប។ ស្រូវចំការនេះត្រូវបានគេដាំជាលក្ខណៈគ្រួសារក្នុងខេត្តកំពង់ចាម ក្រចេះ សៀមរាប កំពង់ធំ កោះកុង កំពត ស្ទឹងត្រែង មណ្ឌលគីរី រតនៈគីរី និង ព្រះវិហារ ។ ប្រភេទស្រូវចំការទាំងនេះភាគច្រើនមាននៅតាមតំបន់ខ្ពង់រាប គឺស្ថិតនៅតាមតំបន់ព្រៃភ្នំ ជំរាលភ្នំ ជើងភ្នំ ដែលដាំដុះដោយជនជាតិភាគតិចជាប្រភេទកសិកម្មពនេចរ រឺកសិកម្មព្រៃដុត ដូចនេះស្រូវចំការក៏ត្រូវបានគេ ស្គាល់ផងដែរថាជាស្រូវភ្នំ ។ ប្រពៃណីរបស់ជនជាតិភាគតិច គឺគេធ្វើចំការដោយការកាប់រំរានព្រៃ ដុតសំអាត រើគរ កំទេចមែកសំណល់ដែលឆេះមិនអស់ហើយបុកដាំដោយគ្រាប់ស្ងួតនៅពេលភ្លៀងដំបូងក្នុងកំឡុងខែឧសភា ហើយជួនកាលគេដាំដុះចំរុះ រឺដាំឆ្លាស់ជាមួយដំណាំដទៃទៀតដូចជា ពោត ល្ង សណ្តែក ហើយការប្រមូលផលអាចចាប់ផ្តើមក្នុងខែតុលា ។ ស្រូវប្រភេទនេះក៏អាចធ្វើការដាំដុះផងដែរនៅលើប្រភេទដីចំការ នៅលើដីទួល ដីកោះ ដោយធ្វើការដាំដុះជាដំណាំចំរុះជាមួយដំណាំដទៃទៀតដូចជា ពោត សណ្តែកបាយ សណ្តែកដី ដាំលើដីចំការតាមតំបន់ខ្ពង់រាប ជាដំណាំតាមចន្លោះជួរ ដំណាំឈើហូបផ្លែមាន ស្វាយ ស្វាយចន្ទី ខ្នុរ កៅស៊ូ ។ល។

ពូជស្រូវដែលរំដោះដោយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ហើយសមស្របបំផុតសំរាប់តំបន់ទាំងនេះជាពូជស្រូវស្រាលដែលមានអាយុកាលចាប់ពី៩០ថ្ងៃទៅ១១០ថ្ងៃ មានពីរពូជគឺ ពូជរាមកេរ្តិ៍ និងសីតា ។

### ២.២.២ ដំណាំស្រូវទំនាបអាស្រ័យទឹកភ្លៀង

ផ្ទៃដីសំរាប់ដាំដុះស្រូវវស្សាប្រមាណជាង៩០%គឺជាផ្ទៃដីដាំដុះស្រូវតំបន់ទំនាបអាស្រ័យទឹកភ្លៀង ។ ស្រូវស្រែទំនាបអាស្រ័យរបបទឹកភ្លៀងនេះត្រូវបានគេដាំដុះគ្រប់ខេត្តទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា។ ប៉ុន្តែតំបន់ដែលមានវិសាលភាពធំធេងជាងគេបំផុត គឺនៅវាលទំនាបជុំវិញបឹងទន្លេសាប ទន្លេមេគង្គ និងទន្លេបាសាក់ ។ ស្រូវនៅក្នុងតំបន់

នេះត្រូវបានគេដាំនៅលើប្រភេទដីផ្សេងៗគ្នាហើយដោយផ្អែកទៅតាមរយៈពេលនៃការលូតលាស់ ឬនៅពេលចេញផ្កា គេចែកប្រភេទពូជស្រូវនៅក្នុងតំបន់នេះជាបីប្រភេទសំខាន់ៗគឺ ប្រភេទពូជស្រូវស្រាល ស្រូវកណ្តាល និងស្រូវធ្ងន់។

**ក- ស្រូវស្រាល**

ពូជស្រូវស្រាលគឺពូជស្រូវដែលមានអាយុកាលលូតលាស់តិចជាង ១២០ថ្ងៃដែលត្រូវបានគេដាំដុះនៅលើផ្ទៃដីប្រមាណជា២០% នៃផ្ទៃដីនៃទំនាបអាស្រ័យទឹកភ្លៀង។ជាទូទៅពូជនេះមិនប្រកាន់រដូវទេគេអាចដាំវានៅក្បែរភូមិ នៅតំបន់ទំនាបខ្ពស់ (ជាដីទំនាបសំរាប់ដំណាំស្រូវដែលមានដក់ទឹក រយៈពេលខ្លីជាងតំបន់ទំនាបទាប) ដែលអាចមានទឹកស្រោចស្រពបាន ។ ក្នុងពេលថ្មីៗនេះកសិករភាគច្រើនបានដាំពូជទាំងនេះនៅដើមរដូវវស្សា។ បន្ទាប់ពីប្រមូលផលពូជស្រូវនេះហើយ ពួកគាត់អាចដាំស្រូវកណ្តាលឬស្រូវធ្ងន់បានទៀត។ នៅតំបន់ផ្សេងទៀតកសិករបានដាំពូជស្រូវទាំងនេះនៅពេលទឹកស្រក ដូច្នេះពូជស្រូវនេះត្រូវបានគេហៅថា ពូជស្រូវប្រដេញទឹក ។

**ខ- ស្រូវកណ្តាល**

ប្រមាណជា ៤០ % នៃផ្ទៃដីដាំដុះស្រូវវស្សា គឺត្រូវបានគេដាំដុះស្រូវកណ្តាល ។ ជាទូទៅពូជស្រូវកណ្តាលនេះត្រូវបានគេដាំនៅក្នុងតំបន់ទំនាបមធ្យម (ជាដីទំនាបសំរាប់ដំណាំស្រូវដែលនៅចន្លោះរវាងតំបន់ទំនាបខ្ពស់ និងតំបន់ទំនាបទាប) ដែលសមស្របទៅនឹងការលូតលាស់នៃដំណាំស្រូវ ។ ពូជស្រូវកណ្តាលចែកចេញជាពីរក្រុម គឺពូជស្រូវកណ្តាលអវេទរស និងរយៈពន្លឺ (មិនប្រកាន់រដូវ) និងពូជស្រូវកណ្តាលវេទរសនិងរយៈពន្លឺ (ប្រកាន់រដូវ)។ ពូជស្រូវមិនប្រកាន់រដូវ គឺមានអាយុកាលលូតលាស់ច្រើនជាង ១២០ ថ្ងៃ ប៉ុន្តែមិនលើសពី ១៥០ ថ្ងៃទេ ។ ចំណែកឯពូជស្រូវកណ្តាលប្រកាន់រដូវ ចេញផ្កាចន្លោះពេលពាក់កណ្តាលខែតុលាដល់ពាក់កណ្តាលខែវិច្ឆិកានៃឆ្នាំ។

**គ- ស្រូវធ្ងន់**

ប្រហែលជា ៣៣%នៃផ្ទៃដីទំនាបទីពឹងទឹកភ្លៀងត្រូវបានគេដាំដុះស្រូវធ្ងន់។ ស្រូវធ្ងន់គឺជាស្រូវដែលមានអាយុកាលលូតលាស់វែងមានវេទរសភាពនិងរយៈពន្លឺ (ប្រកាន់រដូវ) និងចេញផ្កានៅរវាងពាក់កណ្តាលខែវិច្ឆិកានៃឆ្នាំ ។ គេដាំវានៅតំបន់ទំនាបទាបដែលជាដីទំនាបសំរាប់ដំណាំស្រូវលិចទឹករយៈពេលយូរជាងតំបន់ទំនាបមធ្យម ។របបទឹកភ្លៀងមិនទៀងទាត់ដែលជាហេតុបណ្តាលអោយមានទាំងគ្រោះរាំងស្ងួតនិងទឹកជំនន់ធ្វើអោយកសិករមានទំនោរទៅរកការដាំដុះស្រូវកណ្តាលជំនួសស្រូវធ្ងន់វិញ ។

### ២.២.៣ ដំណាំស្រូវឡើងទឹក

ស្រូវឡើងទឹក ត្រូវបានគេដាំនៅជុំវិញបឹងទន្លេសាប ក្បែរទន្លេមេគង្គ និងទន្លេបាសាក់ នៅក្នុងខេត្តកំពង់ធំ បន្ទាយមានជ័យ និងបាត់ដំបង ។ តំបន់ដាំដុះស្រូវនេះមានទំហំតូច គេឃើញមាននៅក្នុងខេត្តសៀមរាប ពោធិ៍សាត់ កណ្តាល និងតាកែវ។ ប្រមាណជា ៤%នៃផ្ទៃដីដាំដុះសរុបត្រូវបានគេដាំស្រូវឡើងទឹក។ តំបន់ដាំដុះស្រូវស្ថិតក្នុងប្រព័ន្ធបរិស្ថាននេះមានការថយចុះយ៉ាងឆាប់រហ័សដោយសារគេបានកែប្រែតំបន់នេះទៅដាំដុះស្រូវប្រាំង ឬស្រូវប្រដេញទឹកវិញដោយបុកអណ្តូងដើម្បីយកទឹកស្រោចស្រព។ ក្នុងប្រព័ន្ធកសិ្យត្រ-បរិស្ថាននេះ ស្រូវអាចដុះក្នុងជំរៅទឹកបានដល់ទៅ ៤ម៉ែត្រ ។ ការដាំដុះចាប់ផ្តើមនៅពេលធ្លាក់ភ្លៀងដំបូងក្នុងខែមេសា រឺខែឧសភា បន្ទាប់ពីភ្ជួររាស់គេធ្វើការពង្រួសគ្រាប់ស្ងួត ។ ការធ្វើស្មៅនៅពេលទឹកឡើងចូលស្រែ ពេលវេលាប្រមូលផលរហូតទៅដល់ ខែមករា ។ ពូជស្រូវដែលគេដាំក្នុង

តំបន់នេះ គេប្រើតែពូជស្រូវធ្ងន់ប្រកាន់រដូវ ។ ដំណាំស្រូវក្នុងបរិស្ថាននេះ គេចាត់ទុកថាជាដំណាំយថាផលដោយកសិករពុំអាចគ្រប់គ្រងលើការងារដាំដុះបានទាំងស្រុង គឺអាស្រ័យលើលក្ខខណ្ឌធម្មជាតិទាំងស្រុង ជួនដំណាំត្រូវខូចខាតដោយគ្រាប់មិនដុះពេលព្រួសហើយរាំង ជួនដំណាំខូចដោយទឹកជំនន់ឡើងលឿនពេក ស្រូវឡើងទឹកពុំទាន់ ហើយទិន្នផលដែលទទួលបានក៏ទាប គុណភាពអង្ករបស់ពូជស្រូវក្នុងបរិស្ថាននេះជាប្រភេទអង្ករបាយរឹង ហើយភាគច្រើនអង្ករមានសម្បុរក្រហម ដែលពុំសមប្រកបសំរាប់ទីផ្សារ ។ កសិករដែលនៅតែបន្តដាំដុះស្រូវឡើងទឹក គឺដោយសារដីស្រែរបស់គាត់គ្មានប្រភពទឹកសំរាប់កែប្រែអោយទៅជាស្រែប្រាំងបាន ។ ការធ្វើស្រូវឡើងទឹក ត្រូវចំណាយកំលាំងពលកម្មតិច ការថែទាំនិងការចំណាយទុនតិចតួច ។ ពូជស្រូវឡើងទឹកជាច្រើន បានបាត់បង់ដាច់ពូជអស់ក្នុងសម័យសង្គ្រាមរវាងឆ្នាំ១៩៧០ និងឆ្នាំ១៩៧៨ ដោយកសិករបោះបង់ចោលដីស្រែស្រូវឡើងទឹកទាំងស្រុង ដោយសារអសន្តិសុខ និងការជំលៀសប្រជាជន ។

**២.២.៤ ដំណាំស្រូវប្រាំង ស្រូវប្រដេញទឹកៈ**

ប្រមាណជា ១៣%នៃតំបន់ដាំដុះស្រូវក្នុងប្រទេសកម្ពុជា គឺជាតំបន់ដាំដុះដំណាំស្រូវប្រាំង។ ស្រូវប្រភេទនេះត្រូវបានដាំដុះនៅក្នុងស្រែដែលមានភ្លឺដែលប្រើប្រាស់ទឹកស្រោចស្រពបន្ថែម ឬទាំងស្រុងក្នុងរដូវប្រាំង ឬស្រោចស្រពផ្នែកខ្លះនៅពេលដែលផ្នែកនេះស្ថិតនៅក្នុងស្ថានភាពទឹកថយចុះនៅច្រាំងទន្លេ ។ ជាទូទៅការដាំដុះច្រើនចាប់ផ្តើមពីដើមខែវិច្ឆិកា។ ចំណែកស្រូវប្រដេញទឹកវិញជាចំណែកមួយនៃស្រូវប្រាំងដែលការដាំដុះអនុវត្តមុន ឬលឿនជាងស្រូវប្រាំងដោយអាស្រ័យទៅតាមស្ថានភាពទឹកស្រក ។ ជាទូទៅអាចចាប់ផ្តើមពីខែតុលា ឬខែវិច្ឆិកាដោយស្ទូងប្រដេញទៅតាមទឹកស្រក ។ ពូជស្រូវដែលកសិករប្រើប្រាស់ក្នុងបរិស្ថាននេះ គឺជាពូជទំនើប ឬពូជប្រពៃណីដែលមានអាយុកាលស្រាល អវេទរសនឹងរយៈពន្លឺ (មិនប្រកាន់រដូវ)។

ដំណាំស្រូវរដូវប្រាំងត្រូវបានគេដាំដុះនៅក្នុងខេត្តតាកែវ ព្រៃវែង កណ្តាល និងកំពង់ចាម ។ បច្ចុប្បន្ននេះប្រហែល៧០ទៅ៨០%នៃតំបន់ដាំដុះស្រូវប្រាំង ត្រូវបានគេដាំដុះពូជស្រូវដូចជា អ៊ីអ៊ែរ៦៦ គ្រូ អ៊ីអ៊ែរកេសរ និងសែនពិដោរ និងមានពូជប្រពៃណីមិនប្រកាន់រដូវខ្លះ ត្រូវបានគេនៅតែបន្តការដាំដុះដូចជា ពូជលំអងខ្សាច់ និងនាងសប្រញាប់នៅតាមតំបន់ខ្លះបន្ថែមទៅលើពូជស្រូវអវេទរសនឹងរយៈពន្លឺ (មិនប្រកាន់រដូវ) កសិករដាំពូជស្រូវអវេទរសនឹងរយៈពន្លឺ (ប្រកាន់រដូវ )ក្នុងរដូវប្រាំងផងដែរ តែលើពពួកពូជដែលមានកំរិតប្រកាន់រដូវខ្សោយ ។

**២.៣ ការពិពណ៌នាអំពីលក្ខណៈរបស់ពូជស្រូវដែលត្រូវជ្រើសរើសដើម្បីដាំដុះ**

**- ជំរៅទឹកក្នុងស្រែ**

តំបន់ទំនាបទីពឹងទឹកភ្លៀង ដីស្រែអាចធ្វើការដាំដុះលើគ្រប់ប្រភេទពូជស្រូវ គឺស្រូវស្រាល ស្រូវកណ្តាល និងស្រូវធ្ងន់ ទាំងពពួកអវេទរសនឹងរយៈពន្លឺ (មិនប្រកាន់រដូវ) និងពពួកវេទរសនឹងរយៈពន្លឺ (ប្រកាន់រដូវ) ដោយអាស្រ័យទៅតាមស្ថានភាពដីស្រែ និងស្ថានភាពជំរៅទឹកក្នុងស្រែ ។ សំរាប់ដីស្រែដែលនៅជួរលើក្បែរភូមិដែលមានជំរៅទឹករាក់ពី១០ទៅ៣០សម ភាសាកសិករហៅថា ស្រែលើ សមស្របសំរាប់ពពួកស្រូវស្រាលអវេទរសនឹងរយៈពន្លឺ។ សំរាប់ដីស្រែដែលទាបជាងនេះបន្តិច មានជំរៅទឹកពី៣០ទៅ៤០សម កសិករហៅថា ស្រែកណ្តាល សមស្របសំរាប់ពពួកស្រូវកណ្តាលអវេទរសនឹងរយៈពន្លឺមាន ពូជសន្តិភាព១ សន្តិភាព២ សន្តិភាព៣ ពពូល សារិកា។ ចំពោះដីស្រែដែលមានជំរៅទឹកកាន់តែជ្រៅ កសិករហៅថា ស្រែក្រោម រឺស្រែជំរៅ អាចដាំពពួកពូជ ខា១ ខា២ ខា៣ ខា១១

វ៉ាងជ័យ ។ បើជំរៅទឹកកាន់តែជ្រៅ ជាតំបន់ដីស្រែជ្រៅ ដែលមានជំរៅទឹកចាប់ពី៤០ទៅ៩០សម អាចដាំពពួកស្រូវធ្ងន់ ដែលមានវេទរសនឹងរយៈពន្លឺ គឺពពួកខា៧ ខា៨ ខា៩ ខា១២ និងខា១៣ ។ បើជាតំបន់ដែលមានការជន់លិចខ្លាំងពេល រដូវវស្សាដែលមានជំរៅទឹករហូតដល់ទៅ១៥០សម សមស្របសំរាប់ពពួកស្រូវឡើងទឹក មានពូជទេវតា ដូន និងខាវតាពេជ្រ ដែលជាប្រភេទពូជមានលទ្ធភាពពន្លូតដើមតាមទឹក ។

**-ប្រភេទពូជស្រូវ**

ពូជស្រូវត្រូវបានគេចែកជា២ប្រភេទយ៉ាងច្បាស់លាស់ គឺក្រុមវេទរសភាពនឹងរយៈពន្លឺ (ប្រកាន់រដូវ) និងក្រុមអវេទរសភាពនឹងរយៈពន្លឺ (មិនប្រកាន់រដូវ) ។ ក្រុមវេទរសភាពនឹងរយៈពន្លឺ អាចធ្វើការដាំដុះបានតែ១ដងទេក្នុង១ឆ្នាំ ដោយការចេញផ្កាមានពេលវេលាទាក់ទងទៅនឹងរយៈពន្លឺ ហើយវេទរសភាពនឹងរយៈពន្លឺនេះ អាចធ្វើការវាយតំលៃទៅតាមកំរិតរបស់វា គឺវេទរសភាពនឹងរយៈពន្លឺកំរិតខ្សោយ ដែលដំណាំអាចនឹងចេញផ្កាក្នុងចន្លោះពីថ្ងៃទី១៥ ខែតុលាដល់ថ្ងៃទី១៥ ខែវិច្ឆិកា និងវេទរសភាពនឹងរយៈពន្លឺកំរិតខ្លាំង ដែលដំណាំអាចនឹងចេញផ្កាក្នុងចន្លោះពីថ្ងៃទី១៥ ខែវិច្ឆិកាដល់ថ្ងៃទី៣០ ខែវិច្ឆិកា ។ ពពួកស្រូវនៅក្នុងក្រុមនេះគេពុំអាចកំណត់អាយុកាលអោយបានពិតប្រាកដទេ អាយុកាលនៃដំណាំអាចនឹងខុសគ្នា អាស្រ័យទៅនឹងពេលវេលាដាំដុះ ។ ចំណែកក្រុមអវេទរសភាពនឹងរយៈពន្លឺ អាចចេញផ្កាគ្រប់ពេលវេលា ហើយអាចធ្វើការដាំដុះបានច្រើនដងក្នុង១ឆ្នាំ ប្រសិនជាតំបន់នោះមានទឹកគ្រប់គ្រាន់ក្នុងការធ្វើផលិតកម្ម។ ពូជទាំងនេះមានអាយុកាលច្បាស់លាស់ គិតពីពេលសាបរហូតដល់ពេលច្រូតកាត់ប្រមូលផល ។ គេអាចធ្វើការដាំដុះនៅរដូវប្រាំង ស្រោចស្រពជាស្រូវប្រដេញទឹក និងជាស្រូវដើមរដូវវស្សា ។

**- ភាពធន់ទ្រាំទៅនឹងជម្ងឺ និងសត្វល្អិត**

ពូជស្រូវអនុសាសន៍ចំនួនទាំង៣៥ពូជនេះធ្លាប់បានធ្វើការដាំដុះក្នុងផ្ទះសំណាញ់ ដើម្បីធ្វើពិសោធន៍ឆ្លុះបញ្ចាំងរកភាពធន់ទ្រាំទៅនឹងជម្ងឺ និងសត្វល្អិត ។ ចំពោះជម្ងឺ មានជម្ងឺប្លាស់ ជម្ងឺអ៊ុតត្នោត ។ ចំពោះសត្វល្អិតចង្រៃមាន មមាចត្នោត មមាចបៃតង មូសផ្លុង ដែលយើងបានសង្កេតឃើញថា មានពូជមួយចំនួនមានភាពធន់ទ្រាំទៅនឹងជម្ងឺ និងសត្វល្អិត ដែលការវាយតំលៃនេះយើងបានអោយជាពិន្ទុទៅលើការបំផ្លាញរបស់វា ។

**- កំពស់ដើម**

កំពស់ដើម ក៏ជាកត្តាមួយដែលយើងត្រូវគិតគូរផងដែរ បើជាប្រភេទស្រូវស្រាល កំពស់ត្រូវតែទាបជាងប្រភេទស្រូវកណ្តាល និងប្រភេទស្រូវធ្ងន់ ។ ប៉ុន្តែគេពុំគួរជ្រើសយកពូជដែលមានកំពស់ខ្ពស់ពេកដែរ ពីព្រោះវានាំអោយដួលដើមពេលទុំ ។ ខ្នាតនៃកំពស់ដើមរបស់ពូជនីមួយៗ គេកំណត់ពេលវេលាវាស់វែងនៅដំណាក់កាលស្រូវទុំស្លាបសេក (វាស់ពីផ្ទៃដីដល់ចុងនៃកួរ ) ដែលកំនត់ដោយ

- ទាប មានកំពស់ទាបជាង ៧៥ សម
- មធ្យម មានកំពស់ពី ៨៥-១០៥ សម
- ខ្ពស់មធ្យម មានកំពស់ពី ១១០-១៣០ សម
- ខ្ពស់ មានកំពស់ខ្ពស់ជាង ១៣០ សម

**- ភាពដួលដើម**

ភាពដួល គឺជាការវាយតំលៃលើភាពរឹងមាំរបស់ដងដើមនៃពូជស្រូវនីមួយៗ ជាពិសេសនៅពេលដែលស្រូវទុំ ។ មានពូជភាគច្រើនដែលដួលរាបដល់ដីនៅពេលទុំ ប៉ុន្តែក៏មានពូជខ្លះដែលអាចនៅមានដើម ផ្នែកខ្លះនៅឈរពេល ស្រូវទុំ ចំនុចអវិជ្ជមាននៃការដួលដើមធ្វើអោយស្រូវមានគ្រាប់ស្កកច្រើននាំអោយមានទិន្នផលទាប ។ ស្រូវដួលវ៉ក់វីពុំទៅតាមទិសតែមួយ ធ្វើអោយមានការលំបាកដល់ការច្រូតកាត់ ជាពិសេសពុំសមស្របចំពោះការច្រូតកាត់ដោយគ្រឿង ម៉ាស៊ីន ។ ការដួលដើមពេលស្រូវទុំ បណ្តាលអោយកួរស្រូវប៉ះនឹងផ្ទៃទឹកធ្វើអោយគ្រាប់ស្រូវសើម ហើយគ្រាប់ស្រូវអាចនឹងដុះនៅនឹងកួរ បើជាពូជដែលមានរយះពេលដំណេកខ្លី ។ ដើម្បីធ្វើការវាយតំលៃលើភាពដួលដើម គេត្រូវគិតទៅលើភាគរយនៃដើមដែលដួល និងភាគរយនៃដើមដែលនៅឈរដោយអោយជាពិន្ទុ

- 0 មិនដួល
- 1 ដួលតិចជាង ២0%
- 3 មានដួលដើមពី ២0-៤0 %
- 5 មានដួលដើមពី ៤១-៦0 %
- 7 មានដួលដើមពិ ៦១-៨0 %
- 9 មានដួលដើមលើសពី ៨0 %

**- ភាពស្វិតពេលបោកបែន**

ភាពស្វិតនៃគ្រាប់ក៏ជាកត្តាសំខាន់របស់ពូជដែលកសិករត្រូវគិតគូផងដែរ ពីព្រោះបើគ្រាប់ស្រូវស្វិតពេក វានឹងធ្វើអោយពិបាកនៅពេលបោកបែន បោកពុំបានស្អាតអស់ ធ្វើអោយបាត់បង់ទិន្នផល ។

ជាទូទៅ លទ្ធភាពបោកបែនគេអាចធ្វើការវាយតំលៃដោយយកដៃច្បូតកួរស្រូវដោយទំងន់ដៃស្រាលៗ នៅពេលស្រូវទុំបានប្រហែល៨៥% ។ លក្ខណៈខាងក្រោមនេះ គឺបង្ហាញពីស្ថានភាពស្រូវដែលមានលក្ខណៈពិបាកបោកមធ្យម និងងាយស្រួលបោក។

- 1 ពិបាក បើច្បូតទៅមានតែគ្រាប់ខ្លះប្រហែល ១ % ឬគ្មានគ្រាប់ធ្លាក់សោះ
- 3 ពិបាកមធ្យម បើច្បូតទៅមានប្រហែលពី ១-៥ % គ្រាប់ស្រូវជ្រុះ
- 5 មធ្យម បើច្បូតទៅមានប្រហែលពី ៦-២៥ % គ្រាប់ស្រូវជ្រុះ
- 7 ងាយស្រួល បើច្បូតទៅមានប្រហែលពី ២៦-៥0៥ គ្រាប់ស្រូវជ្រុះ
- 9 ស្រួល បើច្បូតទៅមានគ្រាប់ស្រូវជ្រុះពី ៥១-១00 %

**- អត្រានៃការកិនជាអង្ករ**

អត្រានៃការកិនជាអង្ករ គឺជាលទ្ធភាពរបស់ពូជស្រូវដែលផ្តល់ទៅជាគ្រាប់អង្ករនៅពេលកិនជាអង្ករសំរិត តែកត្តានេះក៏មានទំនាក់ទំនងទៅលើសំណើមគ្រាប់ និងកំរិតភាពទុំនៅក្នុងពេលធ្វើការច្រូតកាត់ បច្ចេកទេសក្រោយការប្រមូលផល ការហាលសំងួត ការរក្សាទុកដាក់ និងគុណភាពរបស់ម៉ាស៊ីនកិនស្រូវផងដែរ ។ អត្រាអង្ករដែលទទួលបានក្រោយពេលកិនមាន អង្ករដើម និងអង្ករចុង ក្នុងនោះមានៈ

- អង្កាម ទទួលបានពី ២0-២២%

- កន្ទក់ ឬចុងអង្កាម   ទទួលបានពី ៨-១០%

- អត្រាអង្ករសុទ្ធ        ទទួលបានពី ៦៨-៧០%

ពូជស្រូវដែលល្អ ក្រោយពេលកិនជាអង្ករ អត្រាកិនជាអង្ករសំរិត អាចទទួលបានពី ៦៨-៧០% នៃបរិមាណស្រូវសរុប ។

**- ភាពទទួលយកនៃអង្ករ**

គឺជាទិដ្ឋភាពទូទៅនៃរូបរាងដែលយើងបានមើលឃើញនូវរូបរាង ពណ៌សម្បុរ និងលក្ខណៈរបស់អង្ករដែលគួរអោយយើងចង់បាន ។

**- ភាពទទួលយកនៃបាយ**

គឺជាទិដ្ឋភាពទូទៅដែលយើងបានមើលឃើញនូវលក្ខណៈរបស់បាយ និងរសជាតិដែលយើងចង់បាន ។

**- ភាពថ្លានៃគ្រាប់អង្ករ**

ជាភាពដែលមើលឃើញនូវភាពថ្លារបស់គ្រាប់អង្ករ ដែលមាននៅលើផ្ទៃទាំងមូលរបស់គ្រាប់អង្ករ ដែលបានអោយជាពិន្ទុដូចខាងក្រោមៈ

- 1 ថ្លា
- 5 មធ្យម
- 9 ស្រអាប់

**- ភាពបាយរឹង**

គុណភាពនៃអង្ករដែលដាំទៅជាបាយមានសភាពរឹង រឺទន់ អង្ករបាយឡើង រឺអង្ករបាយមិនឡើង នេះជាលក្ខណៈរបស់ពូជដែលមានទំនាក់ទំនងទៅនឹងសមាសធាតុគីមី ដែលមាននៅក្នុងគ្រាប់អង្ករ ។ កំរិតភាគរយអាមីឡូសភាពអន្ទិលសីតុណ្ហភាពក្នុងពេលចំអិនភាពរីកមាឌពី អង្ករទៅបាយ ។ សមាសភាពអាមីឡូសអាចនឹងមានការប្រែប្រួលប្រមាណជា ៦% ទៅតាមរដូវដាំដុះ និងអាស្រ័យទៅតាមបរិស្ថានដាំដុះ ហើយខាងក្រោមនេះជាកំរិត សមាសភាពអាមីឡូស អាចកំណត់ពីស្ថានភាពរបស់បាយ ៖

- សមាសភាពអាមីឡូសមានខ្ពស់ជាង ២៥% ជាអង្ករឡើងបាយខ្លាំង (ហៅថាបាយរឹង)
- សមាសភាពអាមីឡូសមានពី ២០-២៥%  ជាអង្ករឡើងបាយមធ្យម (ហៅថាបាយទន់មធ្យម)
- សមាសភាពអាមីឡូសមានពី ១០-២០%  ជាអង្ករមិនឡើងបាយ (ហៅថាបាយទន់)
- សមាសភាពអាមីឡូសមានពី ២-១០%  ជាអង្ករមិនឡើងបាយ (ហៅថាបាយទន់ខ្លាំង)

**- ភាពសពោះនៃគ្រាប់អង្ករ**

ភាពសពោះនៃគ្រាប់អង្ករ ជាភាពដែលមើលឃើញចំនុចសនៅលើផ្ទៃរបស់គ្រាប់អង្ករ ដែលមាននៅលើផ្នែកផ្សេងរបស់គ្រាប់អង្ករ ភាពសពោះមើលឃើញនៅលើផ្នែកផ្សេងនៃគ្រាប់អង្ករ ៖

- សផ្នែកពោះ      ផ្នែកសមាននៅខាងលើផ្នែកពោះនៃគ្រាប់អង្ករ
- សក្នុងបណ្តូល    ផ្នែកសមាននៅខាងក្នុងបណ្តូលនៃគ្រាប់អង្ករ
- សផ្នែកខ្នង       ផ្នែកសមាននៅលើផ្នែកខាងខ្នងនៃគ្រាប់អង្ករ

ភាពសពោះនេះត្រូវបានគេដាក់ពិន្ទុ ដូចខាងក្រោមនេះ ៖

- 0 គ្មានចំនុចសនៅលើគ្រាប់អង្ករ

- 1 តូចផ្ទៃសពោះ តូចជាង 10 %

- 5 មធ្យមផ្ទៃសពោះ មានពី 10-20% ធៀបទៅនឹងផ្ទៃនៃគ្រាប់ទាំងមូល

- 9 ធំផ្ទៃសពោះមានទំហំធំជាង 20% ធៀបទៅនឹងផ្ទៃនៃគ្រាប់ទាំងមូល

**- ប្រវែងគ្រាប់**




ប្រវែងគ្រាប់ គឺជាការវាស់ប្រវែងបណ្តោយគ្រាប់ ដោយគិតចាប់ពីចុងនៃក្បាលគ្រាប់ទៅចុងកន្ទុយគ្រាប់ ដោយគិតខ្នាតជាម.ម(បើគ្រាប់ពូជស្រូវមានកន្ទុយពុំគិតដល់ប្រវែងកន្ទុយទេ)វាស់លើសំណាកចំនួន១០គ្រាប់ និងមានការកំណត់កំរិតដូចខាងក្រោមនេះ ៖

- វែងខ្លាំង វែងជាង ៧,៥៥ ម.ម

- វែង ៦,៦១-៧,៥០ ម.ម

- មធ្យម ៥,៥១- ៦,៦០ ម.ម

- ខ្លី ខ្លីជាង ៥,៥០ ម.ម

**- ទំរង់គ្រាប់**

ទំរងគ្រាប់ គឺជាប្រវែងផលធៀបរវាងប្រវែងបណ្តោយគ្រាប់ លើប្រវែងទទឹងគ្រាប់ ដោយគិតតាមខ្នាតដូចខាងក្រោមនេះ ៖




- វែងរលូន បើវែងជាង ៣,០ ម.ម

- មធ្យម ពី ២,១-៣,០ ម.ម

- ខ្លីកន្តុល ពី១,១-២,០ម.ម

- មូល ១,០ រឺ ខ្លីជាង

**- ក្លិនក្រអូប**

ក្នុងការវាយតំលៃ ទៅលើក្លិនក្រអូបរបស់អង្ករ គឺគេធ្វើតេស្តទៅលើអង្ករនៅដោយប្រើវិញ្ញាណផ្ទាល់ រឺប្រើសូលុយស្យុងគឿះ និងការធ្វើតេស្តទៅលើរសជាតិបាយដោយអោយតំលៃជាពិន្ទុ ៖

0 - គ្មានក្លិនក្រអូប

១ - ក្រអូបតិច

២ - ក្រអូបខ្លាំង

## ៣. ជំហាននៃការជ្រើសរើសពូជស្រូវនៅតំបន់ទំនាប និងសំនួរគន្លឹះដែលទាក់ទងនឹងប្រព័ន្ធក្សេត្រ.បរិស្ថាន ដំណាំស្រូវ

ក្នុងផ្នែកនេះមានគន្លឹះជាច្រើនដើម្បីជួយភ្នាក់ងារផ្សព្វផ្សាយ និងកសិករជ្រើសរើសពូជស្រូវអនុសាសន៍សំរាប់ធ្វើការសាកល្បងធ្វើការបង្ហាញ និងធ្វើការប្រៀបធៀបជាមួយពូជស្រូវកសិករដែលបានដាំក្រោមលក្ខខ័ណ្ឌតំបន់ទំនាបនៅរដូវវស្សា ។ ដូចដែលបានបង្ហាញនៅក្នុងតារាងស្រូវវស្សានៅតំបន់ទំនាបត្រូវបានគេដាំដុះនៅស្រែដែលមានភ្លឺស្រែសំរាប់ទប់ទឹកនៅក្នុងរដូវភ្លៀង ។ គេអាចចែកដីស្រែទំនាបជាបីតំបន់គឺ តំបន់ទំនាបខ្ពស់ ទំនាបមធ្យម និង ទំនាបទាបអាស្រ័យទៅនឹងកំពស់ រយៈពេលដែលគេអាចរក្សាទឹកអោយនៅបាន ។ ជារួមមកដីនៅតំបន់ទំនាបជាដីរំពឹងទឹកភ្លៀងនិងដីដែលត្រូវការស្រោចស្រពផង ។

គន្លឹះផ្សេងៗ ត្រូវបានគេប្រើប្រាស់ដើម្បីជ្រើសរើសពូជស្រូវយោងទៅតាមប្រភេទដីទំនាបនៅក្រោមលក្ខខណ្ឌទាំងនេះគឺ

គន្លឹះទី១ ដីទំនាបខ្ពស់រំពឹងទឹកភ្លៀង

គន្លឹះទី២ ដីទំនាបមធ្យមរំពឹងទឹកភ្លៀង

គន្លឹះទី៣ ដីទំនាបទាបរំពឹងទឹកភ្លៀង

### ៣.១.សំនួរគន្លឹះសំរាប់ការជ្រើសរើសប្រភេទពូជស្រូវនៅតំបន់ទំនាបរំពឹងទឹកភ្លៀង

#### ៣.១.១ គន្លឹះទី១ ការជ្រើសរើសប្រភេទពូជស្រូវនៅតំបន់ទំនាបខ្ពស់រំពឹងទឹកភ្លៀង

១.តើបញ្ហាមមាចត្នោតកើតឡើងញឹកញាប់ទេក្នុងស្រែរបស់អ្នក — បាទ → ជ្រើសរើសពូជ គ្រូ អ៊ីអ៊ែកេសរ និងជលសារ សំរាប់ធ្វើការសាកល្បង ឬការបង្ហាញ

| ទេ ↓

២.តើស្ថានភាពទឹកអាចមាននៅក្នុងស្រែសំរាប់រយះពេល៧៥-៨៥ថ្ងៃ — បាទ → មើលសំនួរទី ៧ (ពូជស្រូវដែលអាចដាំនៅតំបន់ទំនាបខ្ពស់ឬមធ្យម )

| ទេ ↓

៣.តើដាំស្រូវសំរាប់លក់? — បាទ → មើលសំនួរទី៥

| ទេ ↓

៤.ភាពដួល ភាគរយអង្ករ ឬលទ្ធភាពបោក បែន គឺជាបញ្ហាដែលគួរអោយកត់សំគាល់ចំពោះពូជស្រូវដែលអ្នកបានធ្វើ នាពេលបច្ចុប្បន្ននេះ — បាទ → ជ្រើសរើសពូជស្រូវស្រាលបី យោងទៅតាមពិន្ទុដែលទាក់ទងបញ្ហា

| ទេ → ជ្រើសរើសពូជស្រូវស្រាលបី ផ្អែកតាមចំណង់ចំណូលចិត្តរបស់កសិករ

↓

៥.តើមានទីផ្សាក្នុងស្រុកសំរាប់ពូជស្រូវ ក្រអូប — បាទ → ជ្រើសរើសពូជស្រូវសែនពិដោរសំរាប់ធ្វើការសាកល្បង ឬបង្ហាញ

ទេ ↓

៦.តើមានទីផ្សារក្នុងស្រុកសំរាប់ពូជស្រូវរបាយឡើងទេ — បាទ → ជ្រើសរើសពូជបីពី អ៊ីអ៊ែ៦៦ អ៊ីអ៊ែ៧២ គ្រូ ជលសារ បារាយ និង រហាត់ផ្អែកទៅតាមចំណង់ចំណូលចិត្តរបស់កសិករ

ទេ → ជ្រើសរើសពូជ អ៊ីអ៊ែកេសរ និង រំពេសំរាប់ធ្វើការសាកល្បងឬការបង្ហាញ

↓

៧.តើដាំស្រូវសំរាប់លក់ទេ — បាទ → មើលសំនួរទី៩

ទេ ↓

៨.ភាពដួល ភាគរយអង្ករ ឬលទ្ធភាពបោកគឺជាបញ្ហាដែលគួរអោយកត់សំគាល់ចំពោះពូជស្រូវប្រពៃណីដែលអ្នកបានធ្វើ នាពេលបច្ចុប្បន្ននេះ — បាទ → ជ្រើសរើសពូជបី ពីក្រុមពូជស្រូវស្រូវស្រាល (ដាំនៅតំបន់ទំនាបខ្ពស់) និងក្រុមស្រូវកណ្តាល (ដាំនៅតំបន់ទំនាបមធ្យមឬតំបន់ខ្ពស់) ទៅតាមពិន្ទុដែលទាក់ទងបញ្ហា

ទេ → ជ្រើសរើសពូជបី ពីក្រុមពូជស្រូវស្រាល (ដាំនៅតំបន់ទំនាបខ្ពស់) និងក្រុមស្រូវកណ្តាល (ដាំនៅតំបន់ទំនាបមធ្យមឬតំបន់ខ្ពស់) ទៅតាមចំណង់ចំណូលចិត្តរបស់កសិករ

↓

៩.តើមានទីផ្សារ(ក្នុងស្រុក)សំរាប់ពូជស្រូវក្រអូប — បាទ → ជ្រើសរើសពូជសែនពិដោរសំរាប់ធ្វើការសាកល្បងឬបង្ហាញ

ទេ ↓

១០.តើមានទីផ្សារ(ក្នុងស្រុក)សំរាប់ពូជស្រូវអង្ករបាយរឹង — បាទ → ជ្រើសរើសពូជ អ៊ីអ៊ែ៦៦ អ៊ីអ៊ែ៧២ គ្រូ ជលសាបារាយា រហាត់ យោងទៅតាមចំណង់ចំណូលចិត្តរបស់កសិរ

↓ ទេ → ជ្រើសរើសពូជ អ៊ីអ៊ែកេសរ សំរាប់ធ្វើការសាកល្បង ឬការបង្ហាញ

## ៣.១.២ គន្លឹះទី២ ជ្រើសរើសប្រភេទពូជស្រូវនៅតំបន់ទំនាបកណ្តាលពឹងទឹកភ្លៀង

១. មានភ្លៀងទៀងទាត់ និងគ្រប់គ្រាន់ទេរៀងរាល់ឆ្នាំ ហើយជំរៅទឹកក្នុងស្រែតិចជាង ៣០សមប្មទេ — បាទ → មើលសំនួរលេខ៧ (ពូជស្រូវមិនប្រកាន់រដូវប

↓ ទេ

២. តើដាំស្រូវដើម្បីលក់ — បាទ → មើលសំនួរលេខ៥

↓ ទេ

៣.. តើការបំផ្លាញរបស់សត្វមមាចត្នោតគឺជាបញ្ហាសំខាន់នៅក្នុងស្រែរបស់អ្នក — បាទ → ជ្រើសរើសពូជរាំងជ័យ និង ពូជខា៤សំរាប់ធ្វើការសាកល្បង និងធ្វើបង្ហាញ

↓ ទេ

៤. ភាពដួល ភាគរយអង្ករ ឬលទ្ធភាពបោកគឺជាបញ្ហាដែលគួរអោយកត់សំគាល់ចំពោះពូជស្រូវដែលអ្នកបានធ្វើនាពេលបច្ចុប្បន្ននេះ — បាទ → ជ្រើសរើសពូជបីគឺ ពូជខា១-៤ ខា១១ និងរាំងជ័យយោងទៅលើពិន្ទុចំពោះបញ្ហា ដែលពាក់ព័ន្ធ

ទេ → ជ្រើសរើស ពូជខា១-៤ ខា១១ និងរាំងជ័យយោងទៅតាមចំណង់ចំណូលចិត្តរបស់កសិករ

៥.តើមានទីផ្សារក្នុងស្រុកសំរាប់ពូជស្រូវក្រអូប — បាទ → ជ្រើសរើសពូជផ្ការំចេក ផ្ការំចង់ និងផ្ការំដួល សំរាប់ធ្វើការសាកល្បង ឬ បង្ហាញ

↓ ទេ

៦. តើមានទីផ្សារក្នុងស្រុកសំរាប់ពូជស្រូវដែលដាំទៅជាបាយឡើង — បាទ → ជ្រើសរើសពូជ សន្តិភាព២ ៣ ខា១ ខា១១ ពពូលសារិកា និង រាំងជ័យសំរាប់ធ្វើការ សាកល្បង ឬបង្ហាញ

ទេ → ជ្រើសរើសពូជ ខា២ -ខា៦និង សន្តិភាព១ យោងទៅតាមចំនង់ចំនូល ចិត្តរបស់កសិករ

៧. តើការបំផ្លាញរបស់សត្វមមាចត្នោតគឺជាបញ្ហាសំខាន់នៅក្នុងស្រែរបស់អ្នកក — បាទ → ជ្រើសរើសពូជ សន្តិភាព១,២ រាំងជ័យ និងសារិកា យោងទៅតាមចំនង់ចំនូលចិត្តរបស់កសិករ

| ទេ → ជ្រើសរើសពូជ សន្តិភាព ១.២.៣ សារិកា រាំងជ័យ ខា១ ២ ៣ ១១ និងពពូល យោងទៅ តាមការចំនង់ចំនូលចិត្តរបស់កសិករ

## ៣.១.៣ គន្លឹះទី៣: ការជ្រើសរើសប្រភេទពូជស្រូវនៅតំបន់ទំនាបទាប(ស្រែជម្រៅ) ពឹងទឹកភ្លៀង

១. តើការដាំដំណាំឆ្លាស់ស្រូវ-ស្រូវ (ដាំដើមរដូវវស្សា និង ក្នុងរដូវវស្សា) បានអនុវត្តនៅក្នុងស្រែ — បាទ → មើលសំនួរទី៤ (ដំណាំស្រូវដើមរដូវវស្សា )

| ទេ ↓

២. តើការបំផ្លាញរបស់សត្វមមាចត្នោតគឺជាបញ្ហាសំខាន់នៅក្នុងស្រែរបស់អ្នកក — បាទ → ជ្រើសរើសពូជ រាំងជ័យ ខា១២សំរាប់ធ្វើការសាកល្បងប្រៀបធៀបជាមួយពូជដែលធ្លាប់ប្រើបច្ចុប្បន្ន

| ទេ ↓

៣. ភាពដួល ភាគរយអង្កា ឬលទ្ធភាពបោកគឺជាបញ្ហាដែលគួរអោយកត់សំគាល់ចំពោះពូជស្រូវដែលអ្នកបានធ្វើនាពេល បច្ចុប្បន្ននេះ — បាទ → ជ្រើសរើសពូជ ខា៥-៩ និង ១២-១៣ យោងទៅតាមពិន្ទុ សំរាប់កំណត់បញ្ហាដែលទាក់ទង

| ទេ ↓

៤.តើដំណាំស្រូវដើមរដូវវស្សាត្រូវបានគេដាំដើម្បីលក់ — បាទ → មើលសំនួរទី៦

| ទេ ↓

៥.តើសត្វមមាចត្នោតគឺជាបញ្ហសំខាន់ទេ ចំពោះដំណាំស្រូវ ដើមរដូវវស្សា — បាទ → ជ្រើសរើសពូជស្រូវ អ៊ីអ៊ែរ ៦៦ គ្រូ អ៊ីអ៊ែកេសរ បារាយណ៍ និងជលសារ សំរាប់ធ្វើការសាកល្បង និងបង្ហាញ

ទេ → ជ្រើសរើសពូជស្រូវ អ៊ីអ៊ែ៦៦ អ៊ីអ៊ែ៧២ អ៊ីអ៊ែកេសរ គ្រូ បារាយណ៍ រហាត់ ជលសារ រំពេ និង សែនពិដោរ ផ្អែកទៅតាមការចូលចិត្តរបស់កសិករ

៦.តើទីផ្សារក្នុងស្រុកចូលចិត្តពូជស្រូវបាយរឹងទេ — បាទ → ជ្រើសរើសពូជស្រូវ អ៊ីអ៊ែ៦៦ អ៊ីអ៊ែ៧២ គ្រូ បារាយណ៍ និងរំពេ យោងទៅតាមការ ចូលចិត្តរបស់កសិករ។ សំរាប់ដំណាំស្រូវរដូវវស្សាមើល សំនួរទី៧សំរាប់ការជ្រើសរើសពូជដំណាំទី២

ទេ → ជ្រើសរើសពូជ អ៊ីអ៊ែកេសរ ជលសារនិង សែនពិដោរ សំរាប់ដំណាំដើមរដូវវស្សា។ សំរាប់ដំណាំស្រូវរដូវវស្សាមើល សំនួរទី៧សំរាប់ការជ្រើសរើសពូជដំណាំទី២

៧.ទឹកភ្លៀងទៀងទាត់ និង គ្រប់គ្រាន់ទេរៀងរាល់ឆ្នាំ ហើយជំរៅទឹកក្នុងស្រែតិចជាង ៥០ សមឬទេ? — បាទ → មើលសំនួរទី១០ (ពូជស្រូវធ្ងន់)

ទេ ↓

៨. តើសត្វមមាចត្នោតគឺជាបញ្ហាសំខាន់ទេចំពោះដំណាំស្រូវដើមរដូវវស្សាទេទ — បាទ → ជ្រើសរើសពូជ ខា១២ សំរាប់ធ្វើការ សាកល្បង ឬការបង្ហាញ ប្រៀបធៀប ជាមួយពូជ ដែលធ្លាប់ប្រើក្នុងពេលបច្ចុប្បន្ន

ទេ ↓

៩.ភាពដួលល ភាគរយអង្ករ ឬលទ្ធភាពបោកគឺជាបញ្ហាដែលគួរអោយកត់សំគាល់ ចំពោះពូជស្រូវប្រពៃណីដែលអ្នកបានធ្វើនាពេលបច្ចុប្បន្ននេះ — បាទ → ជ្រើសរើសពូជពីពី ខា៥-៩ និង ១២-១៣ យោងទៅតាមពិន្ទុសំរាប់បញ្ហាដែលទាក់ទង

ទេ → ជ្រើសរើសពូជពីពី ខា៥-៩ និង ១២-១៣ យោងទៅការចំនង់ចំនូលចិត្តរបស់កសិករ

↓

១០.តើស្រូវដាំសំរាប់ប្រើប្រាស់ក្នុងគ្រួសារ — បាទ → ជ្រើសរើសពូជ រាំងជ័យ ខា៤ ៥ ៦ ៧ ៨ ៩ ១២ និង ១៣ សំរាប់ធ្វើការសាកល្បង ឬការបង្ហាញ

ទេ ↓

១១.តើទីផ្សារក្នុងស្រុកត្រូវការអង្កបាយយឡើងឬទេ — បាទ → ជ្រើសរើសពូជ រាំងជ័យ ខា ៧ ៩ ១២ និង ១៣ សំរាប់ធ្វើការសាកល្បង ឫបង្ហាញ

ទេ → ជ្រើសរើសពូជ ខា៤ ៥ ៦ ៨

សំរាប់ធ្វើការសាកល្បង ឬធ្វើការបង្ហាញ

### ៣.២ ការផ្សព្វផ្សាយពូជក្នុងសហគមន៍កសិករ

ការផ្សព្វផ្សាយពូជស្រូវក្នុងស្រទាប់កសិករនៅប្រទេសកម្ពុជា លោកអ្នកគួរធ្វើការអនុវត្តន៍ តាមជំហានដូចខាងក្រោម ៖




### ក-ការរៀបចំផែនការលើស្រែកសិករ

នៅក្នុងការរៀបចំផែនការ លោកអ្នកត្រូវធ្វើការប្រជុំពិភាក្សារវាងក្រុមការងារផ្សព្វផ្សាយ ដោយធ្វើការពិភាក្សាលើចំណុចមួយចំនួនដូចជា ធ្វើការកំណត់ទីតាំងផ្សព្វផ្សាយ កំណត់ប្រភេទពូជស្រូវដែលត្រូវធ្វើការផ្សាយផ្សាយ សកម្មភាពអនុវត្តលើស្រែកសិករ និងកសិករចូលរួមក្នុងដំណើរការនៃការផ្សព្វផ្សាយ ។

- ធ្វើការកំណត់តំបន់ផ្សព្វផ្សាយៈ លោកអ្នកត្រូវធ្វើការកំណត់នូវតំបន់ដែលត្រូវផ្សព្វផ្សាយទៅតាមប្រព័ន្ធកេ្សត្របរិស្ថានក្នុងប្រទេសកម្ពុជា និងផ្តល់អាទិភាពដល់តំបន់ដែលការប្រើប្រាស់ពូជរបស់កសិករនៅមានលក្ខណៈប្រពៃណីនៅឡើយ (ពូជផ្តល់ទិន្នផលទាប) ។

- ការកំណត់ប្រភេទពូជស្រូវ៖ នៅពេលជ្រើសរើសតំបន់រួចរាល់ លោកអ្នកត្រូវធ្វើការកំណត់ប្រភេទពូជទៅតាមប្រព័ន្ធអេកូឡូស៊ីរបស់តំបន់នោះ ដោយអនុវត្តតាមវិធីសាស្ត្រដូចបានអធិប្បាយនៅក្នុងផ្នែកខាងលើ ។
- រៀបចំសកម្មភាពអនុវត្តន៍៖ សកម្មភាពការងារសំខាន់ៗដែលត្រូវធ្វើការរៀបចំរួមមាន ដំណើរការនៃការពិសោធន៍លើស្រែកសិករ ការត្រួតពិនិត្យ តាមដាន ការវាយតម្លៃ និងទិវាស្រែបង្ហាញ និងធ្វើការបែងចែកទៅតាមពេលវេលា សកម្មភាពអនុវត្ត វិធីសាស្ត្រ និងសម្ភារៈប្រើប្រាស់ ។
- ការកំណត់កសិករចូលរួម៖ លោកអ្នកត្រូវធ្វើការកំណត់ចំនួន និងប្រភេទកសិករដែលត្រូវចូលរួមនៅក្នុងដំណើរការនៃការផ្សព្វផ្សាយទៅតាមជំហានដែលត្រូវអនុវត្តដូចជា ការពិសោធន៍បង្ហាញ ការតាមដានកូនស្រែពិសោធន៍ ការវាស់វែងទិន្នន័យប្រៀបធៀប និងការវាយតម្លៃនៅពេលប្រមូលផល ។

**ខ-ការពិសោធន៍បង្ហាញ**

ក្រោយពីបានរៀបចំផែនការផ្សព្វផ្សាយរួចរាល់ លោកអ្នកត្រូវចាប់ផ្តើមដំណើរការពិសោធន៍ពូជស្រូវលើស្រែកសិករផ្ទាល់ទៅតាមពេលវេលាដែលបានកំណត់ (ស្របទៅតាមរដូវកាលដាំដុះរបស់កសិករ) ។ លោកអ្នកគួរធ្វើការពិសោធន៍លើកូនស្រែចំនួន៥កូនស្រែក្នុងមួយឃុំ ដែលអាចតំណាងអោយប្រព័ន្ធអេកូឡូស៊ីណាមួយនៅក្នុងប្រទេសកម្ពុជាយើង ។ ក្នុងការរៀបចំការងារនេះ លោកអ្នកត្រូវអនុវត្តតាមចំណុចមួយចំនួនដូចខាងក្រោម ៖

- ទំនាក់ទំនង និងសហការជាមួយរដ្ឋអំណាចមូលដ្ឋានក្នុងតំបន់ដើម្បីជ្រើសរើសកូនស្រែពិសោធន៍ ។ ក្នុងការពិសោធន៍បង្ហាញ លោកអ្នកគួរធ្វើការជ្រើសរើសកូនស្រែដែលស្ថិតនៅជិតតំបន់រស់នៅរបស់កសិករ និងជាកូនស្រែដែលមានសក្តានុពលខ្ពស់ក្នុងការគ្រប់គ្រងទឹកបាន និងកត្តាចង្រៃបាន (មានទឹកគ្រប់គ្រាន់ និង ចៀសផុតពីការប្រថុយប្រថាននៃសត្វកណ្តុរ ជាដើម) ។
- ធ្វើការប្រជុំជាមួយក្រុមកសិករដែលជាម្ចាស់កូនស្រែ និងកសិករពាក់ព័ន្ធផ្សេងទៀត ដើម្បីបង្ហាញពីសារៈប្រយោជន៍ និងបច្ចេកទេសនៃការងារពិសោធន៍ ។ សំណូមពរអោយកសិករចូលរួម និងអនុវត្តនៅគ្រប់ដំណើរការនៃការងារពិសោធន៍ ដូចជា ការដាំដុះ ការតាមដាន ការថែទាំ និងការប្រមូលផល ។
- រៀបចំនូវសម្ភារៈបន្ថែម សម្រាប់ជួយដល់កសិករលើការងារពិសោធន៍ (បើចាំបាច់) ដែលមានដូចជា ពូជស្រូវពិសោធន៍បង្ហាញ និងការចំណាយចាំបាច់ផ្សេងៗមួយចំនួនទៀត ។
- លោកអ្នកគួរចូលរួមក្នុងដំណើរការពិសោធន៍បង្ហាញជាមួយកសិករផ្ទាល់ ដើម្បីធ្វើការតាមដាន និងសម្របសម្រួលនូវសកម្មភាពអនុវត្តរបស់កសិករ ។
- តាំងបង្ហាញនូវផ្លាកសញ្ញាកូនស្រែពិសោធន៍ ដោយធ្វើការសង្កត់ធ្ងន់ទៅលើប្រភេទពូជ ដែលបានធ្វើការពិសោធន៍បង្ហាញ ដើម្បីអោយកសិកររស់នៅជុំវិញ និងកសិករដែលឆ្លងកាត់អាចធ្វើការកត់សម្គាល់បាន ។ ផ្លាកសញ្ញាកូនស្រែនេះ ត្រូវសរសេរជាលក្ខណៈសាមញ្ញ និងមានលក្ខណៈទាក់ទាញដល់កសិករ ដើម្បីអោយគាត់មានចំណាប់អារម្មណ៍ និងអាចយល់បាន ។

### គ- ការវាស់វែងពីលក្ខណៈវិនិច្ឆ័យពូជ

ការត្រួតពិនិត្យតាមដានការពិសោធន៍បង្ហាញ ត្រូវបានធ្វើឡើងនៅក្នុងកំឡុងពេលលូតលាស់នៃដំណាំស្រូវ និងនៅដំណាក់កាលប្រមូលផល ។ ការងារនេះធ្វើឡើងក្នុងគោលបំណង ធ្វើការបង្ហាញពីលក្ខណៈវិនិច្ឆ័យរបស់ពូជដែលត្រូវធ្វើការផ្សព្វផ្សាយ ដោយធ្វើការប្រៀបធៀបរវាងពូជដែលត្រូវផ្សព្វផ្សាយ ជាមួយពូជដែលកសិករតែងតែប្រើប្រាស់សម្រាប់ដំណើរការផលិតកម្មដំណាំស្រូវរបស់គាត់ ។ ដើម្បីអនុវត្តការងារនេះ លោកអ្នកអាចប្រើប្រាស់នូវវិធីសាស្ត្រមួយចំនួនដូចជា សាលារៀនស្រែកសិករ ការវាស់វែងពីលក្ខណៈវិនិច្ឆ័យពូជ និងទស្សនៈកិច្ចលើស្រែកសិករ ។

- **សាលារៀនស្រែកសិករ** ការបង្កើតឡើងនូវសាលារៀនស្រែកសិករ គឺដើម្បីបណ្តុះបណ្តាលដល់ក្រុមកសិករពីបច្ចេកទេសដាំដុះ និងវិធីសាស្ត្រក្នុងការត្រួតពិនិត្យមើលលក្ខណៈវិនិច្ឆ័យរបស់ពូជ ។ ការងារធ្វើឡើងនៅដំណាក់កាលលូតលាស់នៃដំណាំស្រូវ និងនៅដំណាក់កាលប្រមូលផល ដោយមានការបង្ហាញជាទ្រឹស្តី មេរៀន និងការអនុវត្តន៍ផ្ទាល់នៅលើស្រែបង្ហាញ និងលើស្រែកសិករ ។ កសិករដែលត្រូវចូលរួម នៅក្នុងសាលារៀនស្រែកសិករនេះគួរមានចំនួន២០នាក់ ដែលជាកសិករម្ចាស់កូនស្រែពិសោធន៍ និងកសិករ ជិតខាង ។
- **ទស្សនៈកិច្ចលើស្រែកសិករ** នៅក្នុងពេលដំណាលគ្នាទៅនឹងការអនុវត្តលើស្រែកសិករផ្ទាល់របស់សាលារៀនស្រែកសិករ លោកអ្នកគួរមានការរៀបចំអោយមានជាទស្សនៈកិច្ចលើស្រែកសិករផ្ទាល់ដោយមានការចូលរួមពីកសិករជិតខាងផងដែរ ដើម្បីធ្វើការពិនិត្យ និងការតាមលើកម្រិតនៃការលូតលាស់របស់កូនស្រែបង្ហាញ និងកូនស្រែកសិករដែលស្ថិតនៅជុំវិញ ។

### ឃ- ទិវាស្រែបង្ហាញ

នៅដំណាក់កាលប្រមូលផល មុនពេលច្រូតកាត់(១ឬ២ថ្ងៃ) លោកអ្នកត្រូវរៀបចំអោយមានជាទិវាស្រែ បង្ហាញដល់អ្នកពាក់ព័ន្ធផ្សេងៗនៅក្នុងតំបន់ ដើម្បីធ្វើការវាយតម្លៃពីគុណភាព និងបរិមាណនៃទិន្នផលរបស់ កូនស្រែ បង្ហាញ និងកូនស្រែកសិករ និងធ្វើការផ្សព្វផ្សាយពូជទៅដល់កសិករផ្សេងៗនៅក្នុងតំបន់ និងក្រៅតំបន់ ។ អ្នកដែលត្រូវចូលរួមនៅក្នុងការងារនេះ គួរមានចំនួន ៧០-១០០នាក់ រួមមានមន្ត្រីផ្សព្វផ្សាយកសិកម្ម រដ្ឋអំណាចមូលដ្ឋានក្នុងតំបន់ និងកសិករដែលនៅក្នុងនិងក្រៅតំបន់ ។ នៅក្នុងការងារនេះ លោកអ្នកត្រូវរៀបចំជាទស្សនៈកិច្ចលើស្រែកសិករ ការវាស់វែងទិន្នផល ក្រុមពិភាក្សា និងការបង្ហាញលទ្ធផល ។

- **ទស្សនៈកិច្ចលើស្រែកសិករ** លោកអ្នកត្រូវអនុញ្ញាត្តិអោយអ្នកចូលរួម បានចុះទស្សនាផ្ទាល់លើកូនស្រែពិសោធន៍បង្ហាញ និងកូនស្រែកសិករ ក្រោមការសម្របសម្រួលពីមន្ត្រីផ្សព្វផ្សាយ និងម្ចាស់កូនស្រែ ដោយមានការបង្ហាញពីដំណើរការ និងលទ្ធផលនៃការពិសោធន៍ពូជនេះ ។ កូនស្រែដែលត្រូវបង្ហាញគួរមានចំនួន៥កូនស្រែ តាមតែអាចធ្វើទៅបាន ។
- **ការវាស់វែងទិន្នផល** នៅពេលជាមួយគ្នា ត្រូវធ្វើការវាស់វែងទិន្នផលរបស់ពូជស្រូវ តាមរយៈការច្រូតកាត់ផ្ទាល់នៅលើកូនស្រែពិសោធន៍បង្ហាញ ។ ក្នុងករណីពូជពិសោធន៍ មានទំនាក់ទំនងទៅនឹងគុណភាពពូជ លោកអ្នកត្រូវរៀបចំអោយមានការប្រៀបធៀបគុណភាពពូជពិសោធន៍ ជាមួយពូជក្នុងតំបន់របស់គាត់ ។

- **ក្រុមពិភាក្សា** ក្រោយពីបានទស្សនា និងវាស់វែងទិន្នផលរួចរាល់ លោកអ្នកគួរបង្កើតអោយមានក្រុមពិភាក្សាតូចៗ ដែលមានសមាជិកប្រមាណ១០នាក់ ដើម្បីពិភាក្សាទៅលើលក្ខណៈវិនិច្ឆ័យរបស់ពូជទាំង បរិមាណ និងគុណភាពពូជពិសោធន៍បង្ហាញនិងពូជក្នុងស្រុក និងធ្វើការវាយតម្លៃចុងក្រោយ ។ នៅក្នុងក្រុម នីមួយៗ គួរមានអ្នកសម្របសម្រួលម្នាក់ជាមន្ត្រីផ្សព្វផ្សាយ និងកសិករដែលបានចូលរួមនៅក្នុងសាលារៀនស្រែកសិករ ។
- **ការបង្ហាញលទ្ធផល** ក្រោយពីបានពិភាក្សារួចរាល់ លោកអ្នកត្រូវអោយមានតំណាងធ្វើការបង្ហាញនូវលទ្ធផលនៃការពិភាក្សាទៅតាមក្រុមនីមួយៗ ដល់អ្នកចូលរួមផ្សេងៗទៀត ។ ជាចុងក្រោយអ្នកសម្រប សម្រួល ត្រូវធ្វើការវាយតម្លៃរួមនូវលទ្ធផលនៃការបង្ហាញទាំងនេះ និងធ្វើការសន្និដ្ឋានជាចុងក្រោយដោយបញ្ចប់កម្មវិធីទិវាស្រែបង្ហាញ ។

## ៣.៣. ការចំណាយលើការងារផ្សព្វផ្សាយ

ការចំណាយលើការងារផ្សព្វផ្សាយពីពូជស្រូវទំនើប ប្រែប្រួលទៅតាមចំនួនកូនស្រែពិសោធន៍បង្ហាញ និងចំនួនអ្នកចូលរួមក្នុងដំណើរការផ្សព្វផ្សាយ និងប្រភេទនៃសកម្មភាពផ្សាយ ។ ការចំណាយខាងក្រោមនេះ គឺការចំណាយលើដំណើរការផ្សព្វផ្សាយពូជស្រូវ ដោយមានកូនស្រែបង្ហាញចំនួន ៥ កូនស្រែនៅក្នុងតំបន់ដែលបានកំណត់ជ្រើសរើស ។

### ក.ការរៀបចំផែនការលើស្រែកសិករ

នៅក្នុងការរៀបចំផែនការផ្សព្វផ្សាយ លោកអ្នកត្រូវរៀបចំការប្រជុំពិភាក្សា ដោយមានសមាជិកចូលរួមចំនួន ៥នាក់ (ភ្នាក់ងារផ្សព្វផ្សាយ) ដែលមានរយៈពេល ១ ថ្ងៃ ។

ការចំណាយលើការរៀបចំផែនការផ្សព្វផ្សាយពូជស្រូវ ៖

| *ល.រ* | *មុខចំណាយ* | *ឯកតា* | *បរិមាណ* | *តម្លៃរាយ* | *តម្លៃសរុប* |
|---|---|---|---|---|---|
| ១ | ការចំណាយសម្រាប់ភ្នាក់ងារផ្សព្វផ្សាយ | នាក់ | ៥ | ១០ | ៥០ |
| ២ | អាហារសម្រន់និងភេសជ្ជៈ | នាក់ | ៥ | ១ | ៥ |
| ៣ | សម្ភារៈសម្របសម្រួល | សំរាប់ | ១ | ១០ | ១០ |
| | សរុប | | | ៦៥ ដុល្លារអាមេរិក | |

### ខ.ការចំណាយលើការរៀបចំស្រែពិសោធន៍បង្ហាញ

នៅក្នុងការរៀបចំស្រែបង្ហាញ លោកអ្នកត្រូវរៀបចំការប្រជុំក្រុមកសិករ និងសម្របសម្រួលនៅក្នុងដំណើរការដាំដុះកូនស្រែពិសោធន៍ ។ ការប្រជុំក្រុមកសិករត្រូវធ្វើឡើងរយៈពេល១ថ្ងៃ ដោយមានសមាជិកចូលរួមចំនួន១០នាក់ (ភ្នាក់ងារផ្សព្វផ្សាយ ២នាក់ រដ្ឋអំណាចមូលដ្ឋាន ៣នាក់ និងកសិករ ៥នាក់) ។ ចំពោះការសម្របសម្រួលក្នុងដំណើរការដាំដុះ ត្រូវធ្វើឡើងរយៈពេល ៥ថ្ងៃ ដោយមានការចូលរួមពីមន្ត្រីផ្សព្វផ្សាយចំនួន២នាក់ និង កសិករម្ចាស់កូនស្រែពិសោធន៍បង្ហាញ ។

| ល.រ | មុខចំណាយ | ឯកតា | បរិមាណ | តម្លៃរាយ | តម្លៃសរុប |
|---|---|---|---|---|---|
| ១ | ការចំណាយសំរាប់ភ្នាក់ងារផ្សព្វផ្សាយ | នាក់-ថ្ងៃ | ២ x ៦ | ១០ | ១២០ |
| ២ | អាហារសម្រន់និងភេសជ្ជៈ | នាក់ | ១០ | ១ | ១០ |
| ៣ | អាហារថ្ងៃត្រង់ | នាក់ | ១០ | ១ | ១០ |
| ៤ | សម្ភារៈកូនស្រែពិសោធន៍ | សំរាប់ | ៥ | ... | ... |
| | សរុប | | | ... ដុល្លារអាមេរិក | |

**គ.ការចំណាយលើការវាស់វែងលក្ខណៈវិនិច្ឆ័យពូជ**

ការវាស់វែងលក្ខណៈវិនិច្ឆ័យពូជ ត្រូវបានធ្វើឡើង តាមរយៈសាលារៀនស្រែកសិករ ដែលអនុញ្ញាតអោយកសិករជាអ្នកចូលរួមវាស់វែងដោយផ្ទាល់ ចំពោះស្រែពិសោធន៍និងស្រែបង្ហាញ និងតាមរយៈទស្សនៈកិច្ចលើស្រែកសិករ។ សាលារៀនស្រែកសិករ ត្រូវធ្វើឡើងរយៈពេល ៣ថ្ងៃ គឺ២ថ្ងៃនៅដំណាក់ស្រូវកំណរកំណើតកួរដំបូង និងមួយថ្ងៃនៅដំណាក់កាលប្រមូលផល (មុនពេលច្រូតកាត់ប្រមាណ ៥ថ្ងៃ) ដោយមានកសិករចូលរួមប្រមាណ ២០នាក់។ ចំណែកទស្សនៈកិច្ចលើស្រែកសិករ អាចធ្វើឡើងចំនួន ១ថ្ងៃ ដោយមានកសិករជុំវិញចូលរួមចំនួនប្រមាណ ៣០នាក់ ។

**ការចំណាយលើសាលារៀនស្រែកសិករ**

| ល.រ | មុខចំណាយ | ឯកតា | បរិមាណ | តម្លៃរាយ | តម្លៃសរុប |
|---|---|---|---|---|---|
| ១ | ការចំណាយសម្រាប់ភ្នាក់ងារផ្សព្វផ្សាយ | នាក់-ថ្ងៃ | ២ x ៣ | ១០ | ៦០ |
| ២ | អាហារសម្រន់និងភេសជ្ជៈ | នាក់-ថ្ងៃ | ២០ x ៣ | ១ | ៦០ |
| ៣ | អាហារថ្ងៃត្រង់ | នាក់-ថ្ងៃ | ២០ x ៣ | ១ | ៦០ |
| ៤ | សម្ភារៈកូនស្រែពិសោធន៍ | ថ្ងៃ | ៣ | ៣០ | ៩០ |
| | សរុប | | | ២៧០ ដុល្លារអាមេរិក | |

**ការចំណាយលើទស្សនៈកិច្ចលើស្រែកសិករ**

| ល.រ | មុខចំណាយ | ឯកតា | បរិមាណ | តម្លៃរាយ | តម្លៃសរុប |
|---|---|---|---|---|---|
| ១ | ការចំណាយសម្រាប់ភ្នាក់ងារផ្សព្វផ្សាយ | នាក់ | ២ | ១០ | ២០ |
| ២ | អាហារសម្រន់និងភេសជ្ជៈ | នាក់ | ៥០ | ១ | ៥០ |
| ៣ | អាហារថ្ងៃត្រង់ | នាក់ | ៥០ | ១ | ៥០ |
| ៤ | សម្ភារៈសម្របសម្រួល | ថ្ងៃ | ១ | ២០ | ២០ |
| | សរុប | | | ១៤០ ដុល្លារអាមេរិក | |

**ឃ.ការចំណាយលើទិវាស្រែបង្ហាញ**

ទិវាស្រែបង្ហាញ ត្រូវបានធ្វើឡើងរយៈពេល ១ថ្ងៃ ដោយមានអ្នកចូលរួមប្រមាណ ១០០នាក់ ។

| ល.រ | មុខចំណាយ | ឯកតា | បរិមាណ | តម្លៃរាយ | តម្លៃសរុប |
|---|---|---|---|---|---|
| ១ | ការចំណាយសម្រាប់ភ្នាក់ងារផ្សព្វផ្សាយ | នាក់ | ៥ | ១០ | ៥០ |
| ២ | អាហារសម្រន់និងភេសជ្ជៈ | នាក់ | ១០០ | ១ | ១០០ |
| ៣ | អាហារថ្ងៃត្រង់ | នាក់ | ១០០ | ១ | ១០០ |
| ៤ | ការចំណាយលើការធ្វើដំណើរ | នាក់ | ៥០ | ២ | ១០០ |
| ៥ | សម្ភារៈសម្របសម្រួល | ថ្ងៃ | ១ | ៥០ | ៥០ |
| | សរុប | | | ៤០០ ដុល្លារអាមេរិក | |

**៣.៤. តម្រូវការធនធាននៅក្នុងការងារផ្សព្វផ្សាយ**

ក. ភ្នាក់ងារផ្សព្វផ្សាយ

ភ្នាក់ងារផ្សព្វផ្សាយពីពូជស្រូវទំនើប ត្រូវមានចំណេះដឹងជាមូលដ្ឋានទៅលើលក្ខណៈរបស់ពូជដែលត្រូវផ្សព្វផ្សាយបច្ចេកទេសផលិតកម្មពូជ និងការវាស់វែងពីលក្ខណៈវិនិច្ឆ័យរបស់ពូជ ។ ចំណេះដឹងទាំងនេះអាចទទួលបានតាមរយៈឯកសារទាក់ទងដែលអាចរកបាន និងតាមការបណ្តុះបណ្តាលពីអ្នកឯកទេសពូជស្រូវ ។

ខ. ឯកសារផ្សព្វផ្សាយ

ឯកសារផ្សព្វផ្សាយសំខាន់ៗដែលអាចប្រើប្រាស់ជាជំនួយនៅក្នុងការសម្របសម្រួលលើការងារផ្សព្វផ្សាយ ពីការប្រើប្រាស់ពូជស្រូវទំនើប មានដូចខាងក្រោម ៖

| ល.រ | ឈ្មោះឯកសារផ្សព្វផ្សាយ | ប្រភេទឯកសារ | ប្រភព | ភាសា |
|---|---|---|---|---|
| ១ | ពូជស្រូវ អ៊ីអ៊ែរ ៦៦ | ព្រឹត្តិប្រ័តស្រាវជ្រាវ | CARDI | ខ្មែរ |
| ២ | ពូជស្រូវ អ៊ីអ៊ែរ កេសរ | ព្រឹត្តិប្រ័តស្រាវជ្រាវ | CARDI | ខ្មែរ |
| ៣ | ពូជស្រូវសែនពិដោរ | ព្រឹត្តិប្រ័តស្រាវជ្រាវ | CARDI | ខ្មែរ |
| ៤ | ពូជស្រូវក្រអូបផ្ការំដួល | ព្រឹត្តិប្រ័តស្រាវជ្រាវ | CARDI | ខ្មែរ |
| ៥ | ពូជស្រូវក្រអូបផ្ការំចេក | ព្រឹត្តិប្រ័តស្រាវជ្រាវ | CARDI | ខ្មែរ |
| ៦ | ពូជស្រូវ រាំងជ័យ | ព្រឹត្តិប្រ័តស្រាវជ្រាវ | CARDI | ខ្មែរ |
| ៧ | ពូជស្រូវ ខា ៤ | ព្រឹត្តិប្រ័តស្រាវជ្រាវ | CARDI | ខ្មែរ |
| ៨ | ការពិពណ៌នាអំពីពូជស្រូវដែលបានរំដោះដោយគណកម្មាធិការអនុសាសន៍ពូជដំណាំកម្ពុជា (១៩៩០-២០០២ ) | សៀវភៅ | CARDI | អង់គ្លេស |

## ៣.៥ ថវិកាសម្រាប់ការធ្វើបង្ហាញ

ថវិកាសម្រាប់កម្មវិធីផ្សព្វផ្សាយ នឹងប្រែប្រួលអាស្រ័យលើតម្រូវការជាក់ស្តែងនៃសាមីអង្គភាព។ តារាងថវិកាខាងក្រោមបានបង្កើតឡើងក្នុង ឆ្នាំ២០០៦ ដោយយោងទៅលើការប៉ាន់ស្មានលើបទដ្ឋានអនុវត្តបច្ចេកវិទ្យារបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។

| **ថវិកា និង ការសន្មត់** | ចំនួន/តម្លៃ |
|---|---|
| ក្រុមកសិករ (ក) | ៣០ នាក់ |
| ទុនសម្រាប់ទីកន្លែងធ្វើបង្ហាញ (ខ) | $១៥០ |
| ការបណ្តុះបណ្តាលក្រុមកសិករ (គ)<br>- ឯកសារ, ការណែនាំពីបច្ចេកវិទ្យា បអប | $៣០ |
| ការបណ្តុះបណ្តាលក្រុមកសិករ (ឃ)<br>- អាហារសំរ៉ន់ | $៩០ |
| ទុនចូលរួមពីកសិករគំរូ (ង) | កំលាំងពលកម្ម និង កូនស្រែបង្ហាញ |
| ទិវាស្រែ - អាហារសំរ៉ន់ (ច) | $២៥ |
| ទិវាស្រែ - សំភារៈ (ឆ) | $១០ |
| មន្រ្តីកសិកម្មស្រុក-ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ (ជ)<br>- ការបណ្តុះបណ្តាល, ការត្រួតពិនិត្យទីកន្លែងធ្វើបង្ហាញ | $៤២ |
| មន្រ្តីកសិកម្មស្រុក-ប្រាក់ឧបត្ថម្ភ ថ្លៃធ្វើដំណើរ (ឈ) | $២៤ |
| ការចុះត្រួតពិនិត្យ-តាមដាននៅមូលដ្ឋានដោយអ្នកឯកទេស (ញ) | $២០ |
| សរុប | **$៣៩១** |

### ការសន្មត់ប្រើប្រាស់មាន

ក. ក្នុង បអប មួយ មានក្រុមកសិករ (៣០នាក់) មានកសិករគំរូដែលធ្វើបង្ហាញ ២កន្លែង

ខ. ទុនសំរាប់ធ្វើបង្ហាញអំពីការជ្រើសរើសពូជស្រូវមានៈ ពូជស្រូវ ៣ ប្រភេទ មកពី អេគីប ចំនួន ១០ គក្រ=4១៥ ជី (អុយរ៉េ ដេអាបេ)=4១០ សំភារៈសំរាប់ថ្នាល/ប្លង់មានៈ (បង្គោលឬស្សី ម៉ែត្រសំពត់ ផ្លាកសញ្ញា និងជញ្ជីង)=4៣០ រីឯតម្លៃសំរាប់កសិកររៀបចំកន្លែងបង្ហាញ និង ថែរក្សា= $២០ សរុបទុនសំរាប់បង្ហាញ (១កន្លែង)=4៧៥ ដូច្នេះ ទុនសំរាប់ពីរកន្លែង = $១៥០។

គ. ឯកសារបណ្តុះបណ្តាលបច្ចេកវិទ្យា មានរួមបញ្ចូលទាំងសំភារៈសម្រាប់បង្រៀន មេរៀន ការបញ្ចាំងស្លាយ និងផ្ទាំងរូបភាពធំៗ ដែលជាដំណើរការនៃវិធីសាស្រ្តបង្រៀន ។

ឃ. ការបណ្តុះបណ្តាលក្រុមកសិករមាន ៣វគ្គ មួយវគ្គ មានរយៈពេលមួយថ្ងៃ លើកលែងតែវគ្គ ការធ្វើជីកំប៉ុស្តិ៍ មានតែ ២វគ្គទេ និង ការកំណត់ចំណាត់ថ្នាក់ដី មានមួយវគ្គ

ង. ទុនចូលរួមពីកសិករមានដីស្រែ ៤០០ម២ (៨ ថ្នាល/ប្លង់) ពូជស្រូវក្នុងស្រុក រៀបចំថ្នាល ដកស្ទូង និង ថែរក្សាដំណាំ

ច. ទិវាស្រែមានកន្លះថ្ងៃមានតែម្តងក្នុងវគ្គណាមួយក្នុងចំណោមវគ្គទាំងបី និងអាចមានការចូលរួមពីកសិករនៅក្បែរៗ ភូមិប្រហែល ៤០ ទៅ ៦០នាក់។

ឆ. សំភារៈសម្រាប់ទិវាស្រែរួមមាន ឧឃោសនស័ព្ទ (មេក្រូ) ផ្ទាំងក្រដាសប្លាស្ទិក និងផ្ទាំងបដារូបភាពផ្សេងៗទៀត

ជ. សម្រាប់មន្ត្រីកសិកម្មស្រុក ថវិកាឧបត្ថម្ភរួមមាន ៤ថ្ងៃ សម្រាប់ការជ្រើសរើសទីកន្លែងបង្ហាញ/ការចាប់ផ្តើម/ការត្រួតពិនិត្យតាមដាន។ ចំពោះការបណ្តុះបណ្តាលសម្រាប់ ៣វគ្គ ផ្តល់អោយ ៦ថ្ងៃ និងទិវាស្រែផ្តល់អោយ ២ថ្ងៃ។

ឈ. ប្រាក់ឧបត្ថម្ភសម្រាប់ម៉ូតូ ២ដុល្លាសម្រាប់មួយថ្ងៃ ទាំងអស់ ១២ថ្ងៃ

ញ. មន្ទីរកសិកម្មខេត្ត-អ្នកឯកទេសជំនាញផ្តល់ជំនួយបច្ចេកទេស និងត្រួតពិនិត្យ-តាមដានការបណ្តុះបណ្តាល បអប

## ៤. លក្ខណៈសំខាន់ៗរបស់ពូជស្រូវដែលរំដោះវិទ្យាស្ថាន

### ៤.១.ពូជស្រូវសំរាប់តំបន់ទំនាបខ្ពស់ (ស្រែលើ)

| ឈ្មោះពូជ | ទិន្នផល (ត/ហត) | អាយុកាល (ថ្ងៃ) | កំពស់ដើម (សម) | ចំនួនដើមបែក | ចំនួនគ្រាប់/កួរ | ប្រវែងកួរ (សម) | ប្រវែងគ្រាប់ (មម) | អត្រាអង្ករ (%) | ភាពសពោះ (ពិន្ទុ) | សមាសភាពអាមីឡូស(%) | គុណភាពអង្ករ | គុណភាពបាយ | ក្លិនក្រអូប | ភាពធន់នឹងពភៈ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| អុីអេីរ ៧២ | ៣,៥-៦,០ | ១១០-១២០ | ៧៧-១១៧ | ១២ | ៨៦ | ២៤,៩ | ៧,២ | ៧៣,០ | មធ្យម(៥) | ២៤,២ | ល្អ | មធ្យម | គ្មាន | មិនធន់ |
| អុីអេីរ ៦៦ | ៤,០-៦,៥ | ១០៥-១១៥ | ៨០-១១៨ | ១២ | ៩៥ | ២៥,១ | ៧,២ | ៦៩,០ | មធ្យម(៥) | ២៣,៦ | ល្អណាស់ | ល្អ | គ្មាន | មិនធន់មធ្យម |
| គ្រូ | ៣,៥-៦,០ | ១១០-១១៥ | ៧៩-១២២ | ១៣ | ៨៩ | ២៤,៥ | ៧,០ | ៧២,០ | ធំ(៩) | ២៤,០ | ល្អណាស់ | ល្អ | គ្មាន | ធន់មធ្យម |
| អុីអេីរ កេសរ | ៤,០-៦,០ | ១០៥-១២០ | ៨៤-១២៣ | ៩,៧ | ៨៩ | ២៥,៧ | ៦,៨ | ៧០,០ | មធ្យម(៥) | ២២,៤ | ល្អណាស់ | ល្អណាស់ | គ្មាន | ធន់មធ្យម |
| បារាយណ៍ | ៤,០-៦,០ | ១០០-១១៥ | ៧៤-៩៤ | ១០,១ | ១០៥ | ២២។៧ | ៦,៨ | ៦៧,២ | តូច(១) | ២៣,៦ | ល្អ | ល្អណាស់ | គ្មាន | មិនធន់មធ្យម |
| ជលសារ | ៤,០-៦,០ | ៩៥-១១០ | ៧៥-៩៣ | ១០,២ | ១២២ | ២១,៧ | ៦,៨ | ៦៨,០ | តូច(១) | ២២,២ | ល្អ | ល្អ | គ្មាន | ធន់មធ្យម |
| រហាត់ | ៤,០-៦,០ | ១០៥-១២០ | ៨១-៩៦ | ៩,៧ | ១១៥ | ២៤,០ | ៦,៧ | ៦៨,២ | តូច(១) | ២៣,២ | ល្អ | ល្អ | គ្មាន | មិនធន់មធ្យម |
| រំពេ | ៤,០-៦,០ | ១០០-១១៥ | ៧១-៨៧ | ៩,៧ | ១១៨ | ២១,០ | ៦,៥ | ៦៦,៩ | តូច(១) | ២៣,០ | ល្អណាស់ | ល្អណាស់ | គ្មាន | មិនធន់ |
| សែនពិដោរ | ៤,០-៦,០ | ១១៥-១២០ | ១០៣ | | | | | | | | | | ក្រអូប | |

## ៤.២. ពូជស្រូវសំរាប់តំបន់ទំនាបកណ្តាល (ស្រែកណ្តាល)

| ឈ្មោះពូជ | ទិន្នផល (ត/ហត) | អាយុកាល (ថ្ងៃ ចេញផ្កា) | កំពស់ដើម (សម) | ចំនួនដើមបែក | ចំនួនគ្រាប់/កួរ | ប្រវែងកួរ (សម) | ប្រវែងគ្រាប់ (មម) | អត្រាអង្ករ (%) | ភាពសពោះ (ពិន្ទុ) | សមាសភាពអាមីឡូស(%) | គុណភាពអង្ករ | គុណភាពបាយ | ក្លិនក្រអូប | ភាពធន់នឹងពភះ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សន្តិភាព ១ | ៤,0-៦,0 | ១៣0-១៤0 | ១0៦-១៤៧ | ៩,២ | ១១0 | ២៥,៧ | ៧,២ | ៧៣,0 | ធំ(៩) | ២២,៦ | មធ្យម | ល្អ | គ្មាន | មិនធន់មធ្យម |
| សន្តិភាព ២ | ៤,0-៦,0 | ១៣0-១៤0 | ១0៨-១៥0 | ៨,៥ | ១0២ | ២៦,៩ | ៧,៦ | ៧0,0 | តូច(១) | ២៣,៤ | ឡូណាស់ | ល្អ | គ្មាន | មិនធន់មធ្យម |
| សន្តិភាព ៣ | ៤,0-៦,៥ | ១៤0-១៤៥ | ១0៦-១៥៥ | ៩,២ | ១0៥ | ២៧ | ៦,៦ | ៧២,0 | ធំ(៩) | ២៣,៣ | មធ្យម | មធ្យម | គ្មាន | មិនធន់ |
| ពពូល | ៤,0-៦,0 | ១៣0-១៤0 | ៨៤-១១0 | ៨,៩ | ១៤១ | ២៤,0 | ៧,៤ | ៧១,៧ | ធំ(៩) | ២៥,៨ | មធ្យម | ល្អ | គ្មាន | មិនធន់មធ្យម |
| សារិកា | ៤,0-៦,0 | ១៣0-១៤0 | ៨៦-១0៦ | ១0,១ | ១៣៤ | ២៣,៣ | ៧,៣ | ៧0,៤ | មធ្យម(៥) | ២៥,៨ | មធ្យម | ល្អ | គ្មាន | មិនធន់មធ្យម |
| ខា ១ | ២,៥-៤,0 | ២-៩ ខែវិច្ឆិកា | ១២៧-១៧៧ | ៧,២ | ១១៥ | ២៣,៦ | ៦,៤ | ៦៨,0 | តូច(១) | ២៣,២ | ល្អ | ល្អ | គ្មាន | មិនធន់ |
| ខា ២ | ២,៥-៤,0 | ៦-១២ ខែវិច្ឆិកា | ១២៦-១៨៧ | ៧,២ | ១៣0 | ២៤,៣ | ៦,២ | ៦៨,0 | មធ្យម(៥) | ២១,៦ | មធ្យម | ល្អ | គ្មាន | មិនធន់ |
| ខា ៣ | ២,៥-៤,៥ | ៣0 តុលា-៧ វិច្ឆិកា | ១២២-១៦៦ | ៧,៧ | ១១៨ | ២២,៦ | ៦,៤ | ៧៤,0 | ធំ(៩) | ២១,៣ | មធ្យម | ល្អ | គ្មាន | មិនធន់ខ្លាំង |
| ខា ១១ | ២,៥-៤,៥ | ៥-១១ ខែវិច្ឆិកា | ១៣៧-១៧៣ | ៧,៣ | ៩៩ | ២៥,៥ | ៧,៦ | ៦៧,0 | តូច(១) | ២៣,៨ | ឡូណាស់ | ល្អ | គ្មាន | មិនធន់ |
| ផ្ការំចេក | ៣,0-៥,0 | ២៥ តុលា-១ វិច្ឆិកា | ១១២-១៦៣ | ៦,៨ | ១២៦ | ២២,0 | ៧,៥ | ៦៧,៨ | គ្មាន(0) | ១៧,៣ | ឡូណាស់ | ល្អណាស់ | ក្រអូប | មិនធន់មធ្យម |
| ផ្ការំចង់ | ៣,0-៥,0 | ២៥ តុលា-១ វិច្ឆិកា | ១0៥-១៥៤ | ៥,៩ | ១២៩ | ២២,0 | ៧,៥ | ៦៧,៦ | គ្មាន(0) | ១៨,0 | ល្អប្រសើរ | ល្អណាស់ | ក្រអូប | មិនធន់មធ្យម |
| ផ្ការំដួល | ៣,៥-៥,៥ | ៣0 តុលា-៧ វិច្ឆិកា | ១0៧-១៧១ | ៧,៨ | ១៣៣ | ២២,៧ | ៧,៥ | ៦៧,៧ | តូច(១) | ២៣,៤ | ឡូប្រសើរ | ល្អណាស់ | ក្រអូប | មិនធន់ |

## ៤.៣.ពូជស្រូវសំរាប់តំបន់ទំនាបទាប (ស្រែវស្សា)

| ឈ្មោះពូជ | ទិន្នផល (ត/ហត) | អាយុកាល (ថ្ងៃចេញផ្កា) | កំពស់ដើម (សម) | ចំនួនដើមបែក | ចំនួនគ្រាប់/កួរ | ប្រវែងកួរ (សម) | ប្រវែងគ្រាប់ (មម) | អត្រាអង្ករ (%) | ភាពសពោះ (ពិន្ទុ) | សមាសភាពអាមីឡូស(%) | គុណភាពអង្ករ | គុណភាពបាយ | ក្លិនក្រអូប | ភាពធន់នឹងពាក់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ខា ៤ | ២,៥-៥,០ | ៨-១៥ ខែវិច្ឆិកា | ១៣២-១៧៣ | ៦,៩ | ១៦០ | ២២,៩ | ៦,៤ | ៧០,០ | តូច(១) | ២១,៣ | ល្អ | ល្អ | គ្មាន | មិនធន់មធ្យម |
| ខា ៦ | ២,៥-៥,០ | ៩-១៦ ខែវិច្ឆិកា | ១២៩-១៧៧ | ៦,៩ | ១៥៥ | ២២,៨ | ៦,៦ | ៧២,០ | មធ្យម(៥) | ២១,៦ | ល្អ | ល្អ | គ្មាន | មិនធន់ |
| ខា ៧ | ២,៥-៤,០ | ១៥-២១ ខែវិច្ឆិកា | ១៤៧-២០៥ | ៦,៧ | ១៥៤ | ២៥,៩ | ៦,២ | ៧៣,០ | តូច(១) | ២៥,១ | ល្អ | ល្អ | គ្មាន | មិនធន់ខ្លាំង |
| ខា ៨ | ២,៥-៤,៥ | ១៩-២៦ ខែវិច្ឆិកា | ១៤៦-១៩៩ | ៦,៩ | ១៩០ | ២៣,៨ | ៥,៨ | ៦៩,០ | មធ្យម(៥) | ២២,៦ | ល្អ | ល្អ | គ្មាន | មិនធន់ |
| ខា ៩ | ២,៥-៤,៥ | ១០-១៧ ខែវិច្ឆិកា | ១៤០-១៨២ | ៧,១ | ១៥៧ | ២៥,៩ | ៦,៤ | ៧០,០ | តូច(១) | ២៣,៦ | ល្អ | ល្អ | គ្មាន | មិនធន់ |
| ខា ១២ | ២,៥-៤,៥ | ១៧-២៤ ខែវិច្ឆិកា | ១៤៩,០ | ៧,៣ | ១៤៣ | ២៥,៣ | ៦,៦ | ៦៧,០ | មធ្យម(៥) | ២៦,០ | ល្អ | ល្អ | គ្មាន | ធន់មធ្យម |
| ខា ១៣ | ២,៥-៤,៥ | ១៩-២៦ ខែវិច្ឆិកា | ១៥៤,០ | ៧,៤ | ១៣៩ | ២៤,៣ | ៥,៩ | ៦៨,០ | មធ្យម(៥) | ២៣,០ | ល្អ | ល្អ | គ្មាន | មិនធន់ |

## លក្ខណៈពិសេសៗរបស់ពូជស្រូវរំដោះសំរាប់តំបន់ទំនាបរំពឹងទឹកភ្លៀង

| ពូជ | ប្រភេទស្រែ | ជំរៅទឹក (សម) | វេទសភាព នឹងពន្លឺ | ប្រភេទពូជ | ពេលចេញផ្កា អាយុកាល | កំពស់ ដើម | ទិន្នផល (ត/ហត) | អត្រាកិន ជាអង្ករ(%) | ភាពឆ្លើយតប នឹងការប្រើជី | ប្រវែង គ្រាប់ | ទំរង់ គ្រាប់ | ភាពស ពោះ | ភាពថ្លា របស់គ្រាប់ | ក្លិនក្រអូប | គុណភាព អង្ករ | គុណភាព បាយ | ភាពបាយ រឹង | ភាពធន់ទ្រាំនឹង មមាចត្នោត |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **អ៊ីអ៊ែរ ៦៦** | ស្រែលើ | 0-២0 | អវេទសនឹងពន្លឺ | ស្រាល | ១០០-១១៥ | ៩៩ | ៤,០-៦,៥ | ៦៩ | ខ្ពស់ | វែង | វែង | មធ្យម | ថ្លា | គ្មាន | ៤.២ | ២.៩ | រឹងមធ្យម | ៣ |
| **អ៊ីអ៊ែរ ៧២** | ស្រែលើ | 0-២0 | អវេទសនឹងពន្លឺ | ស្រាល | ១១០-១២០ | ៩៧ | ៣,៥-៦,០ | ៧៣ | ខ្ពស់ | វែង | វែង | មធ្យម | ថ្លា | គ្មាន | ៣ | ២.៣ | រឹងមធ្យម | ២ |
| **គ្រូ** | ស្រែលើ | 0-២0 | អវេទសនឹងពន្លឺ | ស្រាល | ១០០-១១៥ | ១០១ | ៣,៥-៦,០ | ៧២ | ខ្ពស់ | មធ្យម | វែង | ធំ | ថ្លា | គ្មាន | ៤.៤ | ៣.៤ | រឹងមធ្យម | ៤ |
| **អ៊ីអ៊ែរ កេសរ** | ស្រែលើ | 0-២0 | អវេទសនឹងពន្លឺ | ស្រាល | ១០៥-១២០ | ១០៤ | ៤,០-៦,០ | ៧០ | ខ្ពស់ | មធ្យម | វែង | មធ្យម | ថ្លា | គ្មាន | ៣.៧ | ៣.៧ | រឹងមធ្យម | ៤ |
| **រហាត់** | ស្រែលើ | 0-២0 | អវេទសនឹងពន្លឺ | ស្រាល | ១០៥-១២០ | ៨៩ | ៤,០-៦,០ | ៦៨ | ខ្ពស់ | មធ្យម | វែង | តូច | ថ្លា | គ្មាន | ៣.២ | ២.៥ | រឹងមធ្យម | ៣ |
| **ជលសារ** | ស្រែលើ | 0-២0 | អវេទសនឹងពន្លឺ | ស្រាល | ៩៥-១១០ | ៨៤ | ៤,០-៦,០ | ៦៨ | ខ្ពស់ | មធ្យម | វែង | តូច | មធ្យម | គ្មាន | ៣.១ | ៣.១ | រឹងមធ្យម | ៤ |
| **បារាយណ៍** | ស្រែលើ | 0-២0 | អវេទសនឹងពន្លឺ | ស្រាល | ១០០-១១៥ | ៨៤ | ៤,០-៦,០ | ៦៧ | ខ្ពស់ | មធ្យម | វែង | តូច | ថ្លា | គ្មាន | ៣.៣ | ៣.៥ | រឹងមធ្យម | ៣ |
| **រំពេរ** | ស្រែលើ | 0-២0 | អវេទសនឹងពន្លឺ | ស្រាល | ១០០-១១៥ | ៧៩ | ៤,០-៦,០ | ៦៧ | ខ្ពស់ | មធ្យម | វែង | តូច | ថ្លា | គ្មាន | ៣.៨ | ៣.៧ | រឹងមធ្យម | ២ |
| **សែនពិដោរ** | ស្រែលើ | 0-២0 | អវេទសនឹងពន្លឺ | ស្រាល | ១១៥-១២០ | ១០៣ | ៤,០-៦,០ | ៍ | ខ្ពស់ | វែង | វែង | តូច | ថ្លា | ក្រអូប | ? | ? | ទន់ | ? |
| **រាំងជ័យ** | ស្រែកណ្ដាល | ២០-៣០ | វេទសនឹងពន្លឺ | កណ្ដាល | សប្ដាហ៍ទី១-ខែវិច្ឆិកា | ១៣៧ | ៣,៥-៥,៥ | ៦៨ | ទាប | មធ្យម | វែង | តូច | ថ្លា | គ្មាន | ៣.៤ | ៣.២ | រឹង | ៣ |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **រំចង់** | ស្រែកណ្តាល | ២០-៣០ | វេទរសនឹងពន្លឺ | កណ្តាល | សប្តាហ៍ទី៤-ខែតុលា | ១៣០ | ៣,០-៥,០ | ៦៨ | ទាប | វែង | វែង | គ្មាន | ថ្លា | ក្រអូប | ៤.៥ | ៣.១ | ទន់ | ៣ |
| **រំចេក** | ស្រែកណ្តាល | ២០-៣០ | វេទរសនឹងពន្លឺ | កណ្តាល | សប្តាហ៍ទី៤-ខែតុលា | ១៣៨ | ៣,០-៥,០ | ៦៨ | ទាប | វែង | វែង | គ្មាន | ថ្លា | ក្រអូប | ៣.៤ | ៣.៥ | ទន់ | ៣ |
| **រំដួល** | ស្រែកណ្តាល | ២០-៣០ | វេទរសនឹងពន្លឺ | កណ្តាល | សប្តាហ៍ទី១-ខែវិច្ឆិកា | ១៣៥ | ៣,៥-៥,៥ | ៦៨ | ទាប | វែង | វែង | តូច | ថ្លា | ក្រអូប | ៤.៤ | ៣.៧ | ទន់ | ២ |
| **សន្តិភាព ១** | ស្រែកណ្តាល | ២០-៣០ | អវេទរសនឹងពន្លឺ | កណ្តាល | ១៣០-១៤០ | ១២៧ | ៤,០-៦,០ | ៧៣ | ខ្ពស់ | វែង | វែង | ធំ | ថ្លា | គ្មាន | ១.៣ | ៣.៥ | រឹងមធ្យម | ៣ |
| **សន្តិភាព ២** | ស្រែកណ្តាល | ២០-៣០ | អវេទរសនឹងពន្លឺ | កណ្តាល | ១៣០-១៤០ | ១២៥ | ៤,០-៦,០ | ៧០ | ខ្ពស់ | វែង | វែង | តូច | ថ្លា | អត់ | ៣.៩ | ២.៦ | រឹងមធ្យម | ៣ |
| **សន្តិភាព ៣** | ស្រែកណ្តាល | ២០-៣០ | អវេទរសនឹងពន្លឺ | កណ្តាល | ១៣៥-១៤៥ | ១៣១ | ៤,០-៦,៥ | ៧២ | ខ្ពស់ | មធ្យម | មធ្យម | ធំ | មធ្យម | គ្មាន | ១.៩ | ២.២ | រឹង | ២ |
| **សារិកា** | ស្រែកណ្តាល | ២០-៣០ | អវេទរសនឹងពន្លឺ | កណ្តាល | ១៣០-១៤០ | ៩៦ | ៣,៥-៥,៥ | ៧០ | ខ្ពស់ | វែង | មធ្យម | មធ្យម | ថ្លា | គ្មាន | ២.៣ | ៣ | រឹង | ៣ |
| **ពពូល** | ស្រែកណ្តាល | ២០-៣០ | អវេទរសនឹងពន្លឺ | កណ្តាល | ១៣០-១៤០ | ៩៧ | ៣,៥-៥,៥ | ៧២ | ខ្ពស់ | វែង | វែង | ធំ | មធ្យម | គ្មាន | ២.៤ | ២.៩ | រឹង | ២ |
| **ខា ១១** | ស្រែកណ្តាល | ២០-៣០ | វេទរសនឹងពន្លឺ | កណ្តាល | សប្តាហ៍ទី១-ខែវិច្ឆិកា | ១៥៥ | ២,,៥-៤,៥ | ៦៧ | ទាប | វែង | វែង | តូច | ថ្លា | គ្មាន | ៤.៧ | ៣.៧ | រឹងមធ្យម | ២ |
| **ខា ១** | ស្រែកណ្តាល | ២០-៣០ | វេទរសនឹងពន្លឺ | កណ្តាល | សប្តាហ៍ទី១-ខែវិច្ឆិកា | ១៥២ | ២,៥-៤,០ | ៦៨ | ទាប | មធ្យម | មធ្យម | តូច | ថ្លា | គ្មាន | ២.៦ | ២.៧ | រឹងមធ្យម | ២ |
| **ខា ២** | ស្រែកណ្តាល | ២០-៣០ | វេទរសនឹងពន្លឺ | កណ្តាល | សប្តាហ៍ទី១-ខែវិច្ឆិកា | ១៥៧ | ២,៥-៤,០ | ៦៨ | ទាប | មធ្យម | មធ្យម | មធ្យម | មធ្យម | គ្មាន | ២.៨ | ៣.៤ | រឹងមធ្យម | ២ |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ខា ៣ | ស្រែកណ្ដាល | ២០-៣០ | វេទរសទឹងពន្លឺ | កណ្ដាល | សប្ដាហ៍ទី១-ខែវិច្ឆិកា | ១៤៤ | ២,៥-៤,៥ | ៧៤ | ទាប | មធ្យម | មធ្យម | ធំ | មធ្យម | គ្មាន | ២.១ | ៣.៣ | ទន់ | ១ |
| ខា ៤ | ស្រែកណ្ដាល | ២០-៣០ | វេទរសទឹងពន្លឺ | កណ្ដាល | សប្ដាហ៍ទី២-ខែវិច្ឆិកា | ១៥៣ | ២,៥-៥,០ | ៧០ | ទាប | មធ្យម | មធ្យម | តូច | ថ្លា | គ្មាន | ២.៩ | ៣.៣ | រឹងមធ្យម | ៣ |
| ខា ៥ | ស្រែជំរៅ | ៣០-៥០ | វេទរសទឹងពន្លឺ | ធ្ងន់ | សប្ដាហ៍ទី២-ខែវិច្ឆិកា | ១៦៣ | ២,៥-៤,៥ | ៦៩ | ទាប | មធ្យម | មធ្យម | មធ្យម | មធ្យម | គ្មាន | ២.៨ | ៣.២ | រឹងមធ្យម | ២ |
| ខា ៦ | ស្រែជំរៅ | ៣០-៥០ | វេទរសទឹងពន្លឺ | ធ្ងន់ | សប្ដាហ៍ទី២-ខែវិច្ឆិកា | ១៥៣ | ២,៥-៥,០ | ៧២ | ទាប | មធ្យម | មធ្យម | មធ្យម | មធ្យម | គ្មាន | ៣ | ៣.៣ | រឹងមធ្យម | ២ |
| ខា ៧ | ស្រែជំរៅ | ៣០-៥០ | វេទរសទឹងពន្លឺ | ធ្ងន់ | សប្ដាហ៍ទី៣-ខែវិច្ឆិកា | ១៧៦ | ២,៥-៤,០ | ៧៣ | ទាប | មធ្យម | មធ្យម | តូច | មធ្យម | គ្មាន | ២.៦ | ២.៥ | រឹង | ១ |
| ខា ៨ | ស្រែជំរៅ | ៣០-៥០ | វេទរសទឹងពន្លឺ | ធ្ងន់ | សប្ដាហ៍ទី៣-ខែវិច្ឆិកា | ១៧៣ | ២,៥-៤,៥ | ៦៩ | ទាប | ខ្លី | មធ្យម | មធ្យម | មធ្យម | គ្មាន | ២.៦ | ២.៧ | រឹងមធ្យម | ២ |
| ខា ៩ | ស្រែជំរៅ | ៣០-៥០ | វេទរសទឹងពន្លឺ | ធ្ងន់ | សប្ដាហ៍ទី២-ខែវិច្ឆិកា | ១៦១ | ២,៥-៤,៥ | ៧០ | ទាប | មធ្យម | មធ្យម | តូច | មធ្យម | គ្មាន | ៣.៦ | ២.៥ | រឹងមធ្យម | ២ |
| ខា ១២ | ស្រែជំរៅ | ៣០-៥០ | វេទរសទឹងពន្លឺ | ធ្ងន់ | សប្ដាហ៍ទី៣-ខែវិច្ឆិកា | ១៤៩ | ២,៥-៤,៥ | ៦៧ | ទាប | មធ្យម | មធ្យម | មធ្យម | មធ្យម | គ្មាន | ៣.៦ | ២.៨ | រឹង | ៤ |
| ខា ១៣ | ស្រែជំរៅ | ៣០-៥០ | វេទរសទឹងពន្លឺ | ធ្ងន់ | សប្ដាហ៍ទី៣-ខែវិច្ឆិកា | ១៥៤ | ២,៥-៤,៥ | ៦៨ | ទាប | ខ្លី | មធ្យម | មធ្យម | ថ្លា | គ្មាន | ៣.៣ | ៣.៤ | រឹងមធ្យម | ២ |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ស្រែលើ | មធ្យម | អវេទរសទឹងពន្លឺ | ស្រាល | ថ្ងៃ | (សម) | កំរិត | (%) | ខ្ពស់ | វែង | មធ្យម | ពិន្ទុ | ថ្លា | ក្រអូប | ពិន្ទុ | ពិន្ទុ | រឹង |
| ស្រែកណ្ដាល | រាក់ | វេទរសទឹងពន្លឺ | កណ្ដាល | កាលបរិច្ឆេទ | | | | ទាប | មធ្យម | វែង | | មធ្យម | គ្មាន | (១-៥) | (១-៥) | រឹងមធ្យម |
| ស្រែជំរៅ | | | ធ្ងន់ | | | | | | ខ្លី | | | | | | | ទន់ |

**ឯកសារយោង**

1.Description of Rice Varieties Released by The Varietals Recommendation Committee of Cambodia (1999-2000)
2. Standard Evaluation System for rice (IRRI, 1996)
3. Rice Germplasm Catalog of Cambodia (I,II,III)
4. Descriptors for rice improving varieties released by CIAP
5. Rice Grain Quality and ITs Evaluation , G.S Sidhu, 1997
6. Descriptors for Rice Oryza sativa
7. Current Status of aromatic and glutinous rice varieties in Cambodia (Dr.Men Sarom, 1997)
8. Annual Research Report ( 1990-2001)
9. Research Notes
10. Report on recommendation varieties and its spreading in the farmers fields